**រាជរដ្ឋាភិបាលកម្ពុជា**

# របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩

## ប្រចាំឆមាសទី២ ឆ្នាំ២០២៥

រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជនជាដៃគូដ៏សំខាន់
និងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃសុក្រ ៦កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការ កែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុង វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩

## ប្រចាំឆមាសទី២ ឆ្នាំ២០២៥

« រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជនជាដៃគូដ៏សំខាន់
និងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច »

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី
ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃសុក្រ ៦កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ត្រូវនឹងថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៦

# បុព្វកថា

ការកសាង និងអភិវឌ្ឍប្រទេសជាតិ គឺជាបេសកកម្មចម្បងរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលទាមទារឱ្យមានការចូលរួមមិនអាចខ្វះបានពីគ្រប់មជ្ឈដ្ឋាន ជាពិសេសវិស័យឯកជន ដែលរាជរដ្ឋាភិបាលគ្រប់អាណត្តិតែងចាត់ទុកជាដៃគូដ៏សំខាន់ និងជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ។ ឈរលើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញ និងកំពុងអនុវត្តយ៉ាងសកម្មនូវ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**» ដែលជាផែនទីបង្ហាញផ្លូវដ៏រឹងមាំសម្រាប់ការអភិវឌ្ឍរយៈពេល៥ឆ្នាំ ក៏ដូចជាការត្រួសត្រាយផ្លូវសម្រាប់រយៈពេល ២៥ ឆ្នាំខាងមុខ ក្នុងគោលដៅដឹកនាំកម្ពុជាឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យ ជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីសម្រេចបាននូវមហិច្ឆតានេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការជាច្រើន ក្នុងនោះការជំរុញនិងអភិវឌ្ឍវិស័យឯកជន ដូចមានក្នុង «**បញ្ចកោណទី៣ នៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១: ការអភិវឌ្ឍវិស័យឯកជន និងការងារ**» បានក្លាយជាប្រធានបទសំខាន់មួយ ដោយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់លើការពង្រឹងយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន។ ប្រធានបទនេះមានគោលដៅជាយុទ្ធសាស្ត្រ ក្នុងការកែលម្អបរិយាកាសធុរកិច្ចនិងវិនិយោគនៅកម្ពុជា សំដៅបង្កើនទំនុកចិត្ត និងភាពប៉ាន់ប្រមាណបាន ដែលជាមូលដ្ឋានចាំបាច់ជួយឱ្យវិស័យឯកជនមានភាពប្រកួតប្រជែង និងអាចបន្តដើរតួយ៉ាងសកម្មក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមបរិបទនៃការវិវត្តសេដ្ឋកិច្ចសកល។

ក្នុងបរិបទនៃការពង្រឹងយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជននេះ ការលើកកម្ពស់ប្រសិទ្ធភាពនៃការតាមដាន និងវាយតម្លៃ គឺជាកិច្ចការអាទិភាពមិនអាចខ្វះបាន។ ក្នុងស្មារតីនេះ ក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ មិនត្រឹមតែបានដាក់ចេញនូវវិធានការមុតស្រួចចំគោលដៅ និងមានភាពប្រាកដនិយមនោះទេ ថែមទាំងបានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការទាំងនោះ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលរៀងរាល់ឆមាស។ ទន្ទឹមនឹងនេះ អង្គវេទិកាបានណែនាំដល់ក្រុមការងារតាមវិស័យទាំងអស់ ត្រូវប្រជុំដោះស្រាយបញ្ហាប្រឈម និងសំណូមពរជូនវិស័យឯកជនឱ្យបានទៀងទាត់ ដោយមិនត្រូវរង់ចាំរហូតដល់ការរៀបចំវេទិកាពេញអង្គឡើយ។ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ ក្នុងចំណោមវិធានការសរុប១៧៩ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ មានវិធានការចំនួន១៦៩ ស្មើនឹង ៩៤,៤% ត្រូវបានដោះស្រាយសម្រេចជាស្ថាពរ និង១០វិធានការទៀត ស្មើនឹង៥,៦% កំពុងស្ថិតក្នុងដំណើរការដោះស្រាយ។

តាមរយៈវឌ្ឍនភាពនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តម ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាប្រធានគណៈកម្មាធិការសម្របសម្រួល

ការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (គ.ស.រ.ជ.) និង **អ្នកឧកញ៉ា គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា ជាប្រធានគណៈកម្មការសម្របសម្រួលក្រុមការងារផ្នែកឯកជន សម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន (គ.ស.ឯ.រ.ជ.) ព្រមទាំងក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការដឹកនាំ- សហការដោះស្រាយបញ្ហាប្រឈមជូនវិស័យឯកជនយ៉ាងសកម្ម និងការរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាសទី២ ឆ្នាំ២០២៥ នេះឡើង។

ភាពជាដៃគូសន្ទនា និងកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងឯកជនកន្លងមក យើងទទួលបាននូវការសាទរ និងវាយតម្លៃខ្ពស់ពីគ្រប់មជ្ឈដ្ឋាន ជាពិសេសពីសំណាក់សហគមន៍ធុរកិច្ច និងវិនិយោគិន។ ជាក់ស្តែងតាមរយៈដំណើរការក្រុមការងារតាមវិស័យទាំង១៦ នៃយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ បញ្ហាប្រឈមនិងសំណូមពរសរុបចំនួន ១៩៨ករណី ត្រូវបានវិស័យឯកជនលើកយកមកពិភាក្សាជាមួយផ្នែកពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល។ ពិតមែនថា ក្នុងចំណោមបញ្ហាប្រឈម និងសំណូមពរទាំងនោះត្រូវបានដោះស្រាយសម្រេចជាស្ថាពរចំនួន ១៧៤ករណី នៅសល់ ២៤ករណីទៀត កំពុងស្ថិតក្នុងដំណើរការដោះស្រាយពុំទាន់ចប់ តែលទ្ធផលនេះបានបង្ហាញយ៉ាងច្បាស់ពីប្រសិទ្ធភាពនៃយន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន បានដំណើរការដោយការយល់គ្នាយ៉ាងពិតប្រាកដ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ បន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងយន្តការភាពជាដៃគូនេះឱ្យកាន់តែមានភាពរស់រវើកបន្ថែមទៀត ដោយប្រកាន់យកអភិក្រមបុរេសកម្ម និងការសន្ទនាដោយបើកចំហរ ដើម្បីប្រែក្លាយសមិទ្ធផលនៃការកែទម្រង់ ទៅជាកាលានុវត្តភាពជាក់ស្តែងសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ក្នុងដំណើរឆ្ពោះទៅសម្រេចឱ្យបាននូវ **"ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០"** ។

ថ្ងៃសុក្រ ៨រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# មាតិកា

**ខ្លឹមសារសង្ខេប** ........ i

I- **សេចក្តីផ្តើម** ........ ១

II- **វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩** ........ ២

ក- វឌ្ឍនភាពជារួម ........ ៣

ខ- វឌ្ឍនភាពតាមក្រសួង ស្ថាប័ន ........ ៦

គ- វឌ្ឍនភាពតាមក្រុមវិធានការ ........ ៧

III- **វឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមក្នុងក្រុមការងារតាមវិស័យក្រោយវេទិកាG-PSF លើកទី១៩** ........ ៨

ក- វឌ្ឍនភាពនៃការដោះស្រាយបញ្ហាដែលវិស័យឯកជនបានលើកឡើងក្នុងឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥ ........ ៨

ខ- វឌ្ឍនភាពនៃការដោះស្រាយបញ្ហាដែលវិស័យឯកជនបានលើកឡើងក្នុងឆមាសទី២ ឆ្នាំ២០២៥ ........ ៩

IV- **សេចក្តីសន្និដ្ឋាននិងទិសដៅការងារបន្ត** ........ ១១

**បញ្ជីពាក្យកាត់** ........ ១៣

**បរិសិដ្ឋ** ........ ១៥

**បរិសិដ្ឋទី១** : វិធីសាស្ត្រតាមដាន ........ ១៦

**បរិសិដ្ឋទី២** : តារាងវឌ្ឍនភាព នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ ... ១៩

**បរិសិដ្ឋទី៣** : តារាងវឌ្ឍនភាពបញ្ហាប្រឈមនិងសំណូមពររបស់ផ្នែកឯកជនលើកឡើងក្នុងក្រុមការងារតាមវិស័យក្រោយវេទិកាG-PSF លើកទី១៩ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ ........ ៣១

**បរិសិដ្ឋទី៤** : កម្រងសំណួរស្ទង់មតិ ........ ៤១

## ខ្លឹមសារសង្ខេប

១- វេទិកាG-PSFលើកទី១៩ ដែលត្រូវបានរៀបចំឡើងនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ចំនួន១១ចំណុច រួមមាន (១) ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ (២) ការសម្រាលបន្ទុកលើអនុលោមភាព (៣) ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ (៤) កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ (៥) ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ (៦) ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍ (៧) ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម (៨) វិស័យធនាគារនិងហិរញ្ញវត្ថុ (៩) វិស័យរ៉ែនិងថាមពល (១០) វិស័យសំណង់និងអចលនទ្រព្យ និង (១១) បញ្ហាផ្សេងៗ។

២- ស្របតាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក.) បានបន្តតាមដានការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់និងការដោះស្រាយបញ្ហាជូនវិស័យឯកជនជាប្រចាំ ដោយបានរៀបចំរបាយការណ៍វឌ្ឍនភាព ចំនួន៣លើក ដោយទទួលបានការឯកភាពពីកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនិងបានផ្សព្វផ្សាយជូនផ្នែកឯកជននិងសាធារណជនជ្រាបផងដែរ។ របាយការណ៍ប្រចាំឆមាសទី២ ឆ្នាំ២០២៥ ជារបាយការណ៍លើកទី៤ និងមានវិសាលភាពគ្របដណ្តប់វឌ្ឍនភាពនៃការអនុវត្តវិធានការមុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ និងវឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមដែលលើកឡើងដោយវិស័យឯកជន ក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ ដែលនៅសេសសល់តាំងពីឆ្នាំ២០២៤មក និងបញ្ហាប្រឈមថ្មីៗក្នុងឆមាសទី២ ឆ្នាំ២០២៥។

៣- វឌ្ឍនភាពប្រចាំឆមាសទី២ ឆ្នាំ២០២៥ នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ សរុបចំនួន១៧៩ មានដូចខាងក្រោម៖

ក- **វឌ្ឍនភាពជារួម** : វិធានការសម្រេចបានពេញលេញមានចំនួន១៦៩ ស្មើនឹង៩៤,៤% កើនឡើងចំនួន៣វិធានការ បើធៀបនឹងការអនុវត្តវិធានការក្នុងឆមាសទី១ ឆ្នាំ២០២៥ ខណៈវិធានការកំពុងត្រូវបានអនុវត្តមានចំនួន១០វិធានការ ស្មើនឹង៥,៦%។ ក្នុងនោះ វិធានការកំពុងត្រូវបានអនុវត្តទាំងអស់ សុទ្ធតែសម្រេចបានវឌ្ឍនភាពសំខាន់ៗ។

ខ- **វឌ្ឍនភាពតាមក្រសួង ស្ថាប័ន** : ក្រសួង ស្ថាប័នដែលមានវឌ្ឍនភាពថ្មីក្នុងការអនុវត្តវិធានការបានសម្រេចពេញលេញ មានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន២វិធានការ(សរុប៣៧ ស្មើនឹង៩០,២%) និងក្រសួងមហាផ្ទៃចំនួន១វិធានការ(សរុប៥ ស្មើនឹង១០០%)។ រីឯក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសាធារណការ និងដឹកជញ្ជូន កំពុងបន្តអនុវត្តវិធានការ ដោយស្ថិតក្នុងបង្គោលចរទី២។

គ- **វឌ្ឍនភាពតាមក្រុមវិធានការ** : ក្រុមវិធានការដែលមានវឌ្ឍនភាពថ្មី ដែលសម្រេចការអនុវត្តវិធានការបានពេញលេញ មានចំនួន២ គឺក្រុមវិធានការទី៦ ចំនួន២(សរុប២០ ស្មើនឹង៩០,៩%) និងក្រុមវិធានការទី១១ ចំនួន១(សរុប៤ ស្មើនឹង៨០%)។

៤- បើក្រឡេកមើលការដោះស្រាយបញ្ហាក្នុងក្រុមការងារតាមវិស័យសេសសល់ពីឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥ សរុបចំនួន១៩៦បញ្ហា ក្នុងនោះបញ្ហាចំនួន១៧២ ស្មើនឹង៨៧,៨%(កើនឡើងចំនួន១២បញ្ហា) ត្រូវបានដោះស្រាយរួចរាល់ ខណៈបញ្ហាដែលកំពុងត្រូវបានដោះស្រាយ មានចំនួន២៤ ស្មើនឹង១២,២% ។ សម្រាប់ឆមាសទី២ ឆ្នាំ២០២៥ ក្នុងចំណោមក្រុមការងារទាំង១៦ មានក្រុមការងារចំនួន៦ គឺក្រុមការងារ «ខ» ក្រុមការងារ «គ» ក្រុមការងារ «ឆ» ក្រុមការងារ «ឈ» ក្រុមការងារ «ដ» និងក្រុមការងារ «ឋ» បានបន្តរៀបចំកិច្ចប្រជុំនិងពិភាក្សាស្វែងរកដំណោះស្រាយជូនវិស័យឯកជន។ ដោយឡែក វឌ្ឍនភាពនៃការដោះស្រាយបញ្ហាថ្មីៗដែលត្រូវបានលើកឡើងនៅឆមាសទី២ ឆ្នាំ២០២៥ មានដូចខាងក្រោម៖

ក- **វឌ្ឍនភាពជារួម** : បញ្ហាថ្មីសរុបចំនួន២ ត្រូវបានដោះស្រាយរួចរាល់ទាំងស្រុង។

ខ- **វឌ្ឍនភាពតាមក្រុមការងារតាមវិស័យ** : បញ្ហាថ្មីដែលត្រូវបានដោះស្រាយរួចរាល់ទាំងស្រុង ត្រូវបានលើកឡើងក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យចំនួន២ គឺក្រុមការងារ «ឆ» ចំនួន១បញ្ហា និងក្រុមការងារ «ឈ» ចំនួន១បញ្ហា។

ជារួម បញ្ហាដែលលើកឡើងក្នុងក្រុមការងារតាមវិស័យក្រោយវេទិកាG-PSF លើកទី១៩ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ សរុបមានចំនួន១៩៨ ក្នុងនោះ១៧៤ ស្មើនឹង៨៧,៩% ត្រូវបានដោះស្រាយរួចរាល់ ហើយបញ្ហាដែលនៅសេសសល់ចំនួន២៤ ស្មើនឹង១២,១% កំពុងត្រូវបានដោះស្រាយ សំដៅឈានទៅសម្រេចបានដំណោះស្រាយវិជ្ជមានសម្រាប់វិស័យឯកជន។

៥- ជាទិសដៅបន្ត គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិកាG-PSF(គ.ស.វ.ជ.) នឹងរៀបចំពិធីផ្សព្វផ្សាយរបាយការណ៍នេះជាសាធារណៈ អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ(MIS) សម្រាប់យន្តការវេទិកាG-PSF រៀបចំនិងដាក់ឱ្យប្រើប្រាស់គេហទំព័រសម្រាប់យន្តការវេទិកាG-PSF បញ្ចប់ការរៀបចំនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅណែនាំស្ដីពីនីតិវិធីប្រតិបត្តិស្តង់ដានៃការរៀបចំ និងការប្រព្រឹត្តទៅនៃយន្តការវេទិកាG-PSF ត្រឹមឆមាសទី១ ឆ្នាំ២០២៦ ព្រមទាំងរៀបចំវេទិកាG-PSF លើកទី២០ នាពេលឆាប់ៗខាងមុខ តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## I- សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការលើកកម្ពស់តួនាទីនិងសិទ្ធិរបស់វិស័យឯកជន ព្រមទាំងចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ។ ឈរលើស្មារតីនេះ វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន(វេទិកាG-PSF) ដែលត្រូវបានចាត់ទុកជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីបើកទូលាយ ត្រូវបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនាពេលនោះ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជានាពេលបច្ចុប្បន្ន**។ នាដើមនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំតម្រង់ទិសប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** វេទិកាG-PSF លើកទី១៩ ត្រូវបានរៀបចំឡើងកាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ កន្លងទៅ ដើម្បីបន្តពិនិត្យនិងដោះស្រាយបញ្ហាប្រឈម សំណូមពរ និងក្តីកង្វល់របស់ផ្នែកឯកជននៅកម្ពុជា។ វេទិកាG-PSF លើកទី១៩ បានដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ចម្បងៗចំនួន១១ចំណុច រួមមាន៖

១- ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ
២- ការសម្រាលបន្ទុកលើអនុលោមភាព
៣- ការសម្រួលដល់ធុរកិច្ចក្រោមដែនសមត្ថកិច្ចពន្ធដារ
៤- កិច្ចសម្រួលពាណិជ្ជកម្មក្រោមដែនសមត្ថកិច្ចគយ
៥- ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ
៦- ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍
៧- ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម
៨- វិស័យធនាគារនិងហិរញ្ញវត្ថុ
៩- វិស័យរ៉ែនិងថាមពល
១០- វិស័យសំណង់និងអចលនទ្រព្យ និង
១១- បញ្ហាផ្សេងៗ។



ដើម្បីធានាបាននូវវឌ្ឍនភាពជាប្រចាំ ប្រសិទ្ធភាព និងសង្គតិភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ព្រមទាំងការដោះស្រាយបញ្ហាជូនវិស័យឯកជន រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចជូនក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(ក.អ.ក.) ក្នុងការតាមដាននិងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការ។ អនុវត្តតាមការប្រគល់ភារកិច្ច ក.អ.ក.បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ ចំនួន៣លើក រួចមកហើយដោយទទួលបានការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គផងដែរ។ របាយការណ៍លើកទី១ មានវិសាលភាពគ្របដណ្តប់ត្រឹមវិធានការដែលបានដាក់ចេញក្នុងវេទិកាG-PSFលើកទី១៩ របាយការណ៍លើកទី២

និងលើកទី៣ ត្រូវបានពង្រីកវិសាលភាពទៅគ្របដណ្តប់បញ្ហាប្រឈមដែលបានលើកឡើងដោយវិស័យឯកជនក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យទាំង១៦ ព្រមទាំងរួមបញ្ចូលនូវការស្ទង់មតិផ្នែកឯកជនថែមទៀតផង។

ស្របតាមការប្រគល់ភារកិច្ច ក.អ.ក.បានបន្តតាមដាននិងវាយតម្លៃវឌ្ឍនភាព ដោយរៀបចំរបាយការណ៍ប្រចាំឆមាសទី២ ឆ្នាំ២០២៥ ដើម្បីបូកសរុបពីវឌ្ឍនភាពបន្តទៀតនៃការអនុវត្តវិធានការមុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSFលើកទី១៩ និងវឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមដែលលើកឡើងដោយវិស័យឯកជន ក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ ដែលនៅសេសសល់ពីឆមាសទី១ ក្នុងឆ្នាំ២០២៥ និងបញ្ហាប្រឈមថ្មីៗក្នុងឆមាសទី២ ឆ្នាំ២០២៥។ ប៉ុន្តែ របាយការណ៍ឆមាសទី២ ឆ្នាំ២០២៥នេះ ពុំបានរួមបញ្ចូលនូវការស្ទង់មតិផ្នែកឯកជនឡើយ។[១]

តាមទម្រង់របាយការណ៍មុនៗ របាយការណ៍វឌ្ឍនភាពនេះ មានរចនាសម្ព័ន្ធសំខាន់ៗ ដូចតទៅ៖

- ខ្លឹមសារសង្ខេប
- សេចក្តីផ្តើម
- វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកា G-PSF លើកទី១៩
- វឌ្ឍនភាពនៃការដោះស្រាយបញ្ហាផ្នែកឯកជនក្រោយវេទិកាG-PSF លើកទី១៩ និង
- សេចក្តីសន្និដ្ឋាននិងទិសដៅការងារបន្ត។

## II- វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩

ការតាមដានវឌ្ឍនភាពនៃការអនុវត្តវិធានការទាំង១៧៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៥ ត្រូវបានបែងចែកជា៣កម្រិត ដូចទៅនឹងឆមាសមុនៗដែរ គឺបានសម្រេចពេញលេញ(ពណ៌បៃតង) កំពុងត្រូវបានអនុវត្ត(ពណ៌ទឹកក្រូច) និងមិនទាន់ត្រូវបានអនុវត្ត(ពណ៌ក្រហម)។ ក្នុងនោះ បង្គោលចរទាំង៣ ដែលត្រូវបានបង្កើតឡើងក្នុងឆមាសទី២ ឆ្នាំ២០២៤ ត្រូវបានបន្តតាមដាន ដើម្បីកំណត់កម្រិតវឌ្ឍនភាពនៃវិធានការកំពុងត្រូវបានអនុវត្តនីមួយៗ ដូចមានរំលេចលម្អិតក្នុងបរិសិដ្ឋទី១(វិធីសាស្រ្តតាមដាន)។ ចំពោះវឌ្ឍនភាពលម្អិតនៃវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលកំពុងត្រូវបានអនុវត្ត មានលម្អិតក្នុងបរិសិដ្ឋទី២។

[១] សូមមើលលម្អិតក្នុងបរិសិដ្ឋទី១ វិធីសាស្រ្តតាមដាន។

## ក- វឌ្ឍនភាពជារួម

**រូបភាពទី១ : វឌ្ឍនភាពជារួមនៃការអនុវត្តវិធានការ ក្នុងឆមាសទី១ ឆ្នាំ២០២៥**

**រូបភាពទី២ : វឌ្ឍនភាពជារួមនៃការអនុវត្តវិធានការ ក្នុងឆមាសទី២ ឆ្នាំ២០២៥**




រូបភាពទី១ : បង្ហាញពីវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលបានរាយការណ៍ជូនកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៥។

រូបភាពទី២ : បង្ហាញពីវឌ្ឍនភាពជារួមនៃការអនុវត្តវិធានការក្នុងឆមាសទី២ ឆ្នាំ២០២៥ ក្នុងនោះ វិធានការដែលបានសម្រេចពេញលេញ មានចំនួន១៦៩វិធានការ ស្មើនឹង៩៤,៤% កើនឡើងចំនួន ៣វិធានការ ស្មើនឹង១,៧ពិន្ទុភាគរយ បើធៀបនឹងការអនុវត្តវិធានការក្នុងឆមាសទី១។ វិធានការចំនួន១០ ស្មើនឹង៥,៦% កំពុងត្រូវបានអនុវត្ត(ស្ថិតក្នុងបង្គោលចរទី២) ថយចុះ៣វិធានការ បើធៀបនឹងឆមាសទី១។

វិធានការកំពុងត្រូវអនុវត្តទាំង១០ ពោលគឺជាវិធានការដែលមិនទាន់ត្រូវបានអនុវត្តពេញលេញនេះ ពុំមានវិធានការណាមួយនៅទ្រឹងនោះទេគឺមានវឌ្ឍនភាពសំខាន់ៗហើយត្រូវបានរុញចុះទៅក្នុងបង្គោលចរទី២។ វិធានការទាំងនោះមានរៀបរាប់ដូចខាងក្រោម៖

១- ក.ស.ហ.វ. ទទួលបន្ទុកដឹកនាំធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម : ជាវឌ្ឍនភាព អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ត្រូវបានដាក់ឆ្លងយន្តការនៃទីស្តីការគណៈរដ្ឋមន្ត្រី រួមទាំងកិច្ចប្រជុំអន្តរក្រសួងនាថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥ និងយោងតាមស្មារតីកិច្ចប្រជុំនេះ និយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.) និងក្រសួងយុត្តិធម៌នឹងត្រូវជួបពិភាក្សាផ្តល់យោបល់ផ្នែកទណ្ឌកម្មពិន័យ។

២- ក.ស.ហ.វ.ទទួលបន្ទុកដឹកនាំធ្វើវិសោធនកម្មប្រកាសស្តីពីកាតព្វកិច្ចរាយការណ៍ហិរញ្ញវត្ថុឱ្យវេងសវនកម្មឯករាជ្យ : ជាវឌ្ឍនភាព ប្រកាសស្តីពីកាតព្វកិច្ចរាយការណ៍ហិរញ្ញវត្ថុឱ្យវេង

សវនកម្មឯករាជ្យ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំ និងយន្តការនានារួចរាល់ ប៉ុន្តែត្រូវរង់ចាំអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម ចូលជាធរមានសិន។

៣- ក.ស.ហ.វ.ទទួលបន្ទុកជំរុញការរៀបចំសទ្ទានុក្រមវាក្យសព្ទគណនេយ្យនិងសវនកម្ម ព្រមទាំងការបកប្រែស្តង់ដាគណនេយ្យនិងសវនកម្មជាភាសាខ្មែរ : ជាវឌ្ឍនភាព សទ្ទានុក្រមវាក្យសព្ទគណនេយ្យនិងសវនកម្ម ត្រូវបានរៀបចំបោះពុម្ពនិងដាក់ឱ្យប្រើប្រាស់ក្នុងកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៥។ បច្ចុប្បន្ន ក្រសួងបានបង្កើតក្រុមការងារបច្ចេកទេសរៀបចំនិងបកប្រែស្តង់ដាគណនេយ្យ ស្តង់ដាសវនកម្ម និងស្តង់ដាពាក់ព័ន្ធជាភាសាខ្មែរ និងត្រៀមរៀបចំការបកប្រែក្នុងឆ្នាំ២០២៦។

៤- ប្រគល់ភារកិច្ចជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក.ស.ហ.វ. និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្របសម្រួល និងដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើការពិនិត្យឡើងវិញនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណទាំងអស់ ក្នុងវិស័យនីមួយៗ ដោយចាប់ផ្តើមពីវិស័យទេសចរណ៍និងវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីលុបចេញឬផ្គួបចូលគ្នានូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណដែលត្រួតស៊ីគ្នា ព្រមទាំងកែសម្រួលនីតិវិធីនិងថ្លៃសេវានៃលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណនីមួយៗ ឱ្យមានភាពច្បាស់លាស់ ពោលគឺធ្វើយ៉ាងណាជានាថាគ្មាននីតិវិធីមួយណាដែលបង្កការលំបាកនិងដែលមិនចាំបាច់ដល់ប្រជា-ពលរដ្ឋឡើយ : ជាវឌ្ឍនភាព យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨ ត្រូវបានដាក់ឱ្យអនុវត្តនិងបាននិងកំពុងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ។ បច្ចុប្បន្នក្រសួងបាននិងកំពុងធ្វើការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធមួយចំនួន ដូចជាក.ឧ.វ.ប.ន. ក.ទ.ច. ក.ស.ក. និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើឌីជីថលូបនីយកម្មសេវាពាក់ព័ន្ធធុរកិច្ច អមជាមួយនឹងការពិនិត្យនិងកែសម្រួលនីតិវិធី និងថ្លៃនៃការផ្តល់សេវារបស់ក្រសួងស្ថាប័នខាងលើផងដែរ។

៥- ប្រគល់ភារកិច្ចជូន ឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក.ស.ក.ដ. ធ្វើវិសោធនកម្មច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងសិក្សាពីបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ប្រភេទរថយន្តនិងប្រភេទផ្លូវ ដែលអាចប្រើប្រាស់បានសម្រាប់ការដំឡើងកម្រិតទម្ងន់រថយន្តដឹកទំនិញពី៤០តោនទៅដល់៤៥តោន : ជាវឌ្ឍនភាព សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់ឆ្នាំ២០១៤ ត្រូវបានដាក់ឆ្លងកិច្ចប្រជុំទីស្តីការគណៈរដ្ឋមន្ត្រី និងបានធ្វើវិសោធនកម្មចំនួន៦មាត្រា ហើយក្រសួងក៏បានប្រជុំពិភាក្សាជាមួយក្រសួងយុត្តិធម៌ ដើម្បីពិនិត្យមើលរួមគ្នាលើមាត្រាដែលពាក់ព័ន្ធនឹងទោសប្បញ្ញត្តិផងដែរ។ បច្ចុប្បន្ន សេចក្តីព្រាងច្បាប់នេះ កំពុងបន្តនីតិវិធីក្នុងការពិនិត្យសម្រេចពីទីស្តីការគណៈរដ្ឋមន្ត្រី និងបញ្ជូនទៅរដ្ឋសភាដើម្បីអនុម័ត។

៦- ក.ទ.ច.ទទួលបន្ទុកបង្កើតខ្សែក្រវាត់បៃតងនៅតាមតំបន់ទេសចរណ៍សំខាន់ៗ ដើម្បីជំរុញការផ្គត់ផ្គង់បន្លែ សាច់របស់ប្រជាកសិករដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ : ជាវឌ្ឍនភាព ក្រសួងបានបង្កើតក្រុម

ការងារសិក្សានិងជំរុញការអនុវត្តវិធានការបង្កើតខ្សែក្រវាត់បៃតងនៅតំបន់ទេសចរណ៍សំខាន់ៗនិង បច្ចុប្បន្នបាននិងកំពុងរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាង ក.ទ.ច.និងក.ស.ក.។

៧- ក.ទ.ច.ទទួលបន្ទុកការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ : ជាវឌ្ឍនភាព ក្រសួងបាន បង្កើតក្រុមការងារសិក្សានិងជំរុញការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ និងបាន រៀបចំផែនការសកម្មភាពគាំទ្រ។ បច្ចុប្បន្ន ក្រសួងបាននិងកំពុងរៀបចំអនុស្សរណៈនៃ ការយោគយល់គ្នារវាងក.ទ.ច.និងក្រសួងបរិស្ថាន។

៨- ក.ស.ក.ទទួលបន្ទុកការពន្លឿនការរៀបចំច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីបង្កើន ទំនុកចិត្តរវាងកសិករនិងក្រុមហ៊ុនប្រមូលទិញ : ជាវឌ្ឍនភាព ក្រសួងបាននិងកំពុងរៀបចំ សេចក្តីព្រាងច្បាប់ខាងលើនិងគ្រោងពិនិត្យលទ្ធភាពរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគី ពាក់ព័ន្ធលើទិដ្ឋភាពរួមរួមមានទិដ្ឋភាពគតិយុត្តនិងយន្តការរបស់រាជរដ្ឋាភិបាលក្នុងការជួយគាំទ្រនិង សម្របសម្រួល។

៩- ក.ជ.ន.ស.ទទួលបន្ទុកចូលរួមជាមួយក្រសួងមហាផ្ទៃ ក្នុងការកំណត់លក្ខខណ្ឌវិនិច្ឆ័យជាក់លាក់ ក្នុង ការផ្តល់ទិដ្ឋាការសម្រាប់ជនបរទេសទទួលសិទ្ធិអនុវត្តតាមយន្តការទាំង៤ គឺ (១)យន្តការតាមរយៈ តំណាងជាជនជាតិខ្មែរ (២)យន្តការតាមរយៈក្រុមហ៊ុនបរធនបាល (៣)យន្តការវិនិយោគតំបន់ ទេសចរណ៍ពិសិដ្ឋ និង(៤)យន្តការសិទ្ធិជួលរយៈពេលវែង ដែលនឹងត្រូវស្នើឡើងដោយក្រសួង មហាផ្ទៃ។ ជាវឌ្ឍនភាព តំណាងក្រសួងជ.ន.ស. បានចូលរួមរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពី«បែបបទ និងនីតិវិធីនៃការអនុញ្ញាតឱ្យជនបរទេសមិនមែនអន្តោប្រវេសន្តចូល ចេញ ឆ្លងកាត់ និងស្នាក់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា» ដែលដឹកនាំរៀបចំដោយក្រសួងមហាផ្ទៃ ហើយបច្ចុប្បន្នក្រសួងមហាផ្ទៃ បាន ដាក់សេចក្តីព្រាងអនុក្រឹត្យនេះ ទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ ប៉ុន្តែពុំទាន់ទទួលបានការអនុម័ត។

១០- ប្រគល់ភារកិច្ចជូនឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រីនិងជាអនុប្រធានទី១ នៃក.អ.ក. រៀបចំ វេទិកាG-PSF ឱ្យបានយ៉ាងហោច២លើក នៅក្នុងអាណត្តិនីមួយៗរបស់រាជរដ្ឋាភិបាល : ជាវឌ្ឍនភាព គ.ស.រ.ជ.បាននិងកំពុងរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពរៀងរាល់ឆមាសជូនរាជរដ្ឋាភិបាលជា ទៀងទាត់ ប្រមូលផ្តុំសំណូមពរ និងបញ្ហាប្រឈមរបស់វិស័យឯកជនតាមរយៈក្រុមការងារទាំង១៦ និងបានធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារតាមវិស័យនីមួយៗ ដើម្បីជាការត្រៀមលក្ខណៈ សម្រាប់ការរៀបចំវេទិកាG-PSF លើកទី២០ នាពេលខាងមុខ។

## ខ- វឌ្ឍនភាពតាមក្រសួង ស្ថាប័ន

**រូបភាពទី៣ : វឌ្ឍនភាពតាមក្រសួង ស្ថាប័នទទួលបន្ទុក ក្នុងឆមាសទី១ ឆ្នាំ២០២៥ និងឆមាសទី២ ឆ្នាំ២០២៥**




សម្រាប់ឆមាសទី២ ឆ្នាំ២០២៥នេះ ក្រសួងដែលសម្រេចបានវឌ្ឍនភាពថ្មីមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ២វិធានការ(សរុប៣៧ ស្មើនឹង៩០,២%) និងក្រសួងមហាផ្ទៃចំនួន១វិធានការ (សរុប៥ ស្មើនឹង១០០%) ដូចមានលម្អិតក្នុងបរិសិដ្ឋទី២។ ដោយឡែក ក្រសួងទេសចរណ៍ ក្រសួង-កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងសាធារណការនិងដឹកជញ្ជូន កំពុងបន្តអនុវត្តវិធានការ ដោយស្ថិតក្នុងបង្គោលចរទី២។

## គ- វឌ្ឍនភាពតាមក្រុមវិធានការ

**រូបភាពទី៤ : វឌ្ឍនភាពតាមក្រុមវិធានការក្នុងឆមាសទី១ ឆ្នាំ២០២៥ និងឆមាសទី២ ឆ្នាំ២០២៥**




រូបភាពទី៤ : បង្ហាញពីវឌ្ឍនភាពនៃការអនុវត្តវិធានការតាមក្រុមវិធានការទាំង១១ ដែលមានចែងក្នុងសេចក្តីជូនដំណឹងលេខ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃវេទិកាG-PSF លើកទី១៩ ក្នុងឆមាសទី១ និងឆមាសទី២ ឆ្នាំ២០២៥។

សម្រាប់ឆមាសទី២ ឆ្នាំ២០២៥ ក្រុមវិធានការមានវឌ្ឍនភាពថ្មី មានចំនួន២ ដូចខាងក្រោម៖

- ក្រុមវិធានការទី៦ សម្រេចការអនុវត្តវិធានការពេញលេញចំនួន២បន្ថែមទៀត សរុបវិធានការបានសម្រេចពេញលេញចំនួន២០ ស្មើនឹង៩០,៩%
- ក្រុមវិធានការទី១១ សម្រេចការអនុវត្តវិធានការបានពេញលេញចំនួន១បន្ថែមទៀត សរុបវិធានការបានសម្រេចពេញលេញចំនួន៤ ស្មើនឹង៨០%។

## III- វឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមក្នុងក្រុមការងារតាមវិស័យក្រោយវេទិកាG-PSF លើកទី១៩

បញ្ហាប្រឈមនិងដំណោះស្រាយក្នុងក្រុមការងារតាមវិស័យ ត្រូវបានតាមដានដោយធ្វើការបែងចែកជា៣កម្រិត រួមមានបញ្ហាបានដោះស្រាយ(ពណ៌បៃតង) បញ្ហាកំពុងដោះស្រាយ(ពណ៌ទឹកក្រូច) និងបញ្ហាមិនទាន់ដោះស្រាយ(ពណ៌ក្រហម)។ ជាការកត់សម្គាល់ ក្រោយវេទិកាG-PSF លើកទី១៩ ក្រុមការងារតាមវិស័យចំនួន១៤ បានរៀបចំកិច្ចប្រជុំដើម្បីពិភាក្សាស្វែងរកដំណោះស្រាយជូនវិស័យឯកជន។

### ក- វឌ្ឍនភាពនៃការដោះស្រាយបញ្ហាដែលវិស័យឯកជនបានលើកឡើងក្នុងឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥

**រូបភាពទី៥ : វឌ្ឍនភាពនៃការដោះស្រាយបញ្ហា ក្នុងក្រុមការងារតាមវិស័យដែលវិស័យឯកជនបានលើកឡើង ក្នុងឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥**




រូបភាពទី៥ : បង្ហាញពីការដោះស្រាយបញ្ហាដែលវិស័យឯកជនបានលើកឡើងក្នុងក្រុមការងារតាមវិស័យ ក្នុងឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥ សរុបចំនួន១៩៦បញ្ហា។ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ វឌ្ឍនភាពបញ្ហាដែលបានដោះស្រាយរួចរាល់ មានចំនួន១៧២ ស្មើនឹង៨៧,៨% កើនឡើងចំនួន១២ ស្មើនឹង៦,២ពិន្ទុភាគរយ បើប្រៀបធៀបនឹងការដោះស្រាយបញ្ហាគិតត្រឹមឆមាសទី១ ឆ្នាំ២០២៥។ ដោយឡែក បញ្ហាដែលនៅសេសសល់កំពុងដោះស្រាយ មានចំនួន២៤ ស្មើនឹង១២,២% ថយចុះ១២បញ្ហា។

**រូបភាពទី៦ : វឌ្ឍនភាពនៃដំណោះស្រាយបញ្ហាតាមក្រុមការងារតាមវិស័យ ក្នុងឆ្នាំ២០២៤ និងឆមាសទី១ ឆ្នាំ២០២៥**




រូបភាពទី៦ : បង្ហាញពីវឌ្ឍនភាពនៃដំណោះស្រាយបញ្ហាតាមក្រុមការងារតាមវិស័យ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥។ ក្រុមការងារដែលមានវឌ្ឍនភាពដោះស្រាយបញ្ហានៅក្នុងឆមាសនេះ មាន៤ក្រុម គឺក្រុមការងារ «ខ» ចំនួន២បញ្ហា ក្រុមការងារ «ឋ» ចំនួន៤បញ្ហា ក្រុមការងារ «ណ» ចំនួន៥បញ្ហា និង ក្រុមការងារ «ត» ចំនួន១បញ្ហា។ សូមមើលបរិសិដ្ឋទី៣ សម្រាប់ព័ត៌មានលម្អិតនៃវឌ្ឍនភាពបញ្ហាដែលត្រូវបានដោះស្រាយគិតត្រឹមឆមាសទី២ ឆ្នាំ២០២៥។

## ខ- វឌ្ឍនភាពនៃការដោះស្រាយបញ្ហាដែលវិស័យឯកជនបានលើកឡើងក្នុងឆមាសទី២ ឆ្នាំ២០២៥

សម្រាប់ឆមាសទី២ ឆ្នាំ២០២៥ ក្រុមការងារចំនួន៦ ក្នុងចំណោម១៦ បានបន្តរៀបចំកិច្ចប្រជុំនិងពិភាក្សាស្វែងរកដំណោះស្រាយជូនវិស័យឯកជន ដែលក្នុងនោះរួមមាន ក្រុមការងារ «ខ» ក្រុមការងារ «គ» ក្រុមការងារ «ឆ» ក្រុមការងារ «ឈ» ក្រុមការងារ «ជ» និងក្រុមការងារ «ឋ»។

ក្នុងឆមាសទី២ ឆ្នាំ២០២៥ បញ្ហាប្រឈមដែលត្រូវបានលើកឡើងដោយវិស័យឯកជនក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យចំនួន២ រួមមានក្រុមការងារ «ឆ» ១បញ្ហា និង «ឈ» ១បញ្ហា សរុប២បញ្ហា ដែលបញ្ហាទាំងពីរនេះត្រូវបានដោះស្រាយរួចរាល់១០០%។ ចំណែកឯក្រុមការងារតាមវិស័យផ្សេងទៀតបានប្រជុំពិភាក្សាស្វែងរកដំណោះស្រាយលើបញ្ហាដែលនៅសេសសល់។ សូមមើលបរិសិដ្ឋទី៣ សម្រាប់ព័ត៌មានលម្អិតនៃបញ្ហានិងដំណោះស្រាយដែលបានលើកឡើងក្នុងឆមាសទី២ ឆ្នាំ២០២៥។

លទ្ធផលនៃកិច្ចប្រជុំរបស់ក្រុមការងារតាមវិស័យចំនួន២ ដែលបានផ្តល់ព័ត៌មាននិងរាយការណ៍គ្រប់ជ្រុងជ្រោយមានដូចខាងក្រោម៖

- ក្រុមការងារ «ធ» ផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម : បានជួបប្រជុំពិភាក្សាជាមួយវិស័យឯកជន ដើម្បីពិនិត្យនិងដោះស្រាយបញ្ហាប្រឈមចំនួន១ ដែលពាក់ព័ន្ធនឹងការសម្របសម្រួលតាំងពិព័រណ៌ផលិតផលខ្មែរនៅបរទេស។ យោងតាមស្មារតីនៃកិច្ចប្រជុំកាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៥ បញ្ហានេះត្រូវបានដោះស្រាយរួចរាល់ទាំងស្រុង។
- ក្រុមការងារ «ឈ» ផ្នែកស្រូវអង្ករ : បានពិនិត្យនិងដោះស្រាយបញ្ហាប្រឈមដែលវិស័យឯកជនបានជួបប្រទះចំនួន១បញ្ហា ពាក់ព័ន្ធនឹងការបញ្ចៀសការធ្លាក់ចុះតម្លៃស្រូវផ្ការំដួល។ យោងតាមស្មារតីកិច្ចប្រជុំកាលពីថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥ បញ្ហានេះត្រូវបានដោះស្រាយរួចរាល់។

## វឌ្ឍនភាពជារួមនៃការដោះស្រាយបញ្ហាក្នុងក្រុមការងារតាមវិស័យ

រូបភាពទី៧ : វឌ្ឍនភាពជារួមនៃការដោះស្រាយបញ្ហាក្នុងក្រុមការងារតាមវិស័យ ក្រោយវេទិកាលើកទី១៩




រូបភាពទី៨ : វឌ្ឍនភាពដំណោះស្រាយបញ្ហា តាមក្រុមការងារតាមវិស័យ ក្រោយវេទិកាលើកទី១៩




បញ្ហាប្រឈមជារួមដែលត្រូវបានលើកឡើងក្នុងក្រុមការងារតាមវិស័យក្រោយវេទិកា លើកទី១៩មានសរុបចំនួន១៩៨ ក្នុងនោះ១៧៤បញ្ហា ស្មើនឹង៨៧,៩% បានដោះស្រាយរួចរាល់ ហើយបញ្ហាដែលនៅសេសសល់ចំនួន២៤(ដូចមានរំលេចក្នុងបរិសិដ្ឋទី៣) ស្មើនឹង១២,១% កំពុងដោះស្រាយ សំដៅឈានទៅសម្រេចបានដំណោះស្រាយវិជ្ជមានសម្រាប់វិស័យឯកជន។ បើក្រឡេកមើលរូបភាពទី៨ បង្ហាញថា ក្រុមការងារតាមវិស័យចំនួន ៩ កំពុងដោះស្រាយបញ្ហាដែលនៅសេសសល់ទាំង២៤។

## IV- សេចក្តីសន្និដ្ឋាននិងទិសដៅការងារបន្ត

របាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការមុតស្រួចដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៥ ត្រូវបានរៀបចំឡើងក្នុងគោលបំណងពិនិត្យលើវឌ្ឍនភាពនៃការអនុវត្តវិធានការមុតស្រួចជាកញ្ចប់ដែលនៅសេសសល់ពីឆមាសមុន និងពិនិត្យមើលលើវឌ្ឍនភាពនៃការដោះស្រាយបញ្ហាប្រឈមដែលវិស័យឯកជនបានលើកឡើងក្នុងក្រុមការងារតាមវិស័យ ក្រោយវេទិកាG-PSF លើកទី១៩។

ជាវឌ្ឍនភាពគិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ ការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិកាG-PSFលើកទី១៩ កាន់តែឈានទៅសម្រេចបានការអនុវត្តពេញលេញ១០០% ដោយវិធានការសេសសល់ត្រូវបន្តអនុវត្ត មានចំនួន១០ប៉ុណ្ណោះ។ បន្ថែមលើនេះ វិធានការកំពុងត្រូវបានអនុវត្តទាំងអស់សុទ្ធតែសម្រេចបានវឌ្ឍនភាពសំខាន់ៗដែលស្ថិតក្នុងបង្គោលចរទី២។ ក្នុងនោះ វិធានការដែលកំពុងអនុវត្តមួយចំនួនគឺពាក់ព័ន្ធនឹងការរៀបចំឬធ្វើវិសោធនកម្មច្បាប់ឬលិខិតបទដ្ឋានគតិយុត្ត និងមួយចំនួនជាវិធានការដែលតម្រូវឱ្យមានការសម្របសម្រួលអន្តរក្រសួងកម្រិតខ្ពស់។ សម្រាប់ការដោះស្រាយបញ្ហានៅក្រុមការងារតាមវិស័យក្រោយវេទិកាG-PSFលើកទី១៩វិញ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥ ត្រូវបានសង្កេតឃើញថាមានភាពល្អប្រសើរ ដោយក្នុងនោះបញ្ហាថ្មីដែលបានលើកឡើងមានចំនួន២ ហើយបញ្ហាដែលនៅសេសសល់ទាំង២៤ កំពុងត្រូវបានដោះស្រាយសំដៅឈានទៅសម្រេចបានដំណោះស្រាយជូនផ្នែកឯកជន។

ការរៀបចំយន្តការG-PSF ដោយមានកិច្ចប្រជុំក្រុមការងារតាមវិស័យជាប្រចាំ ដើម្បីដោះស្រាយសំណូមពររបស់វិស័យឯកជននិងការរៀបចំរបាយការណ៍តាមការចង្អុលបង្ហាញប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** មានប្រសិទ្ធភាពមិនត្រឹមតែការដោះស្រាយសំណូមពររបស់វិស័យឯកជនដែលមានចំពោះមុខប៉ុណ្ណោះទេ ប៉ុន្តែយន្តការនេះបានធ្វើឱ្យមានប្រសិទ្ធភាពលើ៖

- ការពង្រឹងគណនេយ្យភាពនិងតម្លាភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយផ្តល់ព័ត៌មានទៀងទាត់ជូនដល់វិស័យឯកជនពាក់ព័ន្ធនឹងវឌ្ឍនភាពសម្រេចបានក្រោមយន្តការវេទិកាG-PSF និងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តខ្ពស់ ដែលជាសក្ខីកម្មបញ្ជាក់ថារាជរដ្ឋាភិបាលមិនត្រឹមតែយកចិត្តទុកដាក់ស្តាប់នូវក្តីកង្វល់របស់វិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានចាត់វិធានការដោះស្រាយបញ្ហាទាំងនោះយ៉ាងជាក់ស្តែង និងប្រកបដោយប្រសិទ្ធភាព
- ការយល់ដឹងរបស់វិស័យឯកជនស្តីពីទិដ្ឋភាពច្បាប់ និងបច្ចេកទេសពាក់ព័ន្ធនឹងគោលនយោបាយដាក់ចេញដោយរាជរដ្ឋាភិបាល ដែលជាមូលដ្ឋានគ្រឹះនៃការធ្វើធុរកិច្ចមាននិរន្តរភាព ដោយបានឆ្លុះបញ្ចាំងតាមរយៈសំណូមពររបស់វិស័យឯកជនមានការថយចុះក្នុងឆមាសទី២ ឆ្នាំ២០២៥ ក្នុងនោះមានក្រុមការងារខ្លះ មិនមានសំណូមពរចាំបាច់ក្នុងការប្រជុំបែបនេះទៀតផង និង
- ការបង្កើតមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យនិងដាក់ចេញនូវវិធានការបន្ថែមក្រោមដែនសមត្ថកិច្ចរបស់ខ្លួន សំដៅពង្រឹងការអនុវត្តវិធានការដែលបាននៅ

សេសសល់ ការដោះស្រាយបញ្ហាប្រឈមនានា ដែលបានលើកឡើងក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ និងការដោះស្រាយសំណូមពរផ្សេងៗទៀតរបស់វិស័យឯកជន។ល។

ដើម្បីបន្តពង្រឹងប្រសិទ្ធភាពនៃការតាមដាននិងវាយតម្លៃ សម្រាប់ទិសដៅការងារបន្ត គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិកាG-PSF(គ.ស.រ.ជ.) នឹង៖

(១)- រៀបចំពិធីផ្សព្វផ្សាយរបាយការណ៍នេះជាសាធារណៈ ដើម្បីធានាថាវិស័យឯកជន ទទួលបានព័ត៌មានទាន់ពេលវេលានិងមានតម្លាភាពពីវឌ្ឍនភាពនៃការអនុវត្តវិធានការនិងការដោះស្រាយបញ្ហា ក្រោមយន្តការវេទិកាG-PSF។

(២)- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យ(MIS) សម្រាប់យន្តការវេទិកាG-PSF ព្រមទាំងរៀបចំសៀវភៅណែនាំអំពីរបៀបប្រើប្រាស់និងបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធខាងលើ ដើម្បីសម្រួលដល់ការរាយការណ៍របស់ក្រសួង ស្ថាប័នទទួលបន្ទុក។

(៣)- រៀបចំនិងដាក់ឱ្យប្រើប្រាស់គេហទំព័រសម្រាប់យន្តការវេទិកាG-PSF ដើម្បីផ្តល់លទ្ធភាពដល់វិស័យឯកជនក្នុងការទទួលបាននូវព័ត៌មានគ្រប់ជ្រុងជ្រោយពីយន្តការនេះ។

(៤)- បញ្ចប់ការរៀបចំនិងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវសៀវភៅណែនាំស្តីពីនីតិវិធីប្រតិបត្តិស្តង់ដានៃការរៀបចំនិងការប្រព្រឹត្តទៅនៃយន្តការវេទិកាG-PSF ត្រឹមឆមាសទី១ ឆ្នាំ២០២៦ និង

(៥)- រៀបចំវេទិកាG-PSF លើកទី២០ នាពេលឆាប់ៗខាងមុខ តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

## **បញ្ជីពាក្យកាត់**

បញ្ជីពាក្យកាត់សំខាន់ៗជាភាសាខ្មែរ

| | |
|---|---|
| ក្រុមការងារ«ក» | ក្រុមការងារផ្នែកសិកម្ម កសិឧស្សាហកម្ម |
| ក្រុមការងារ«ខ» | ក្រុមការងារផ្នែកទេសចរណ៍ |
| ក្រុមការងារ«គ» | ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូចនិងមធ្យម និងសេវា |
| ក្រុមការងារ«ឃ» | ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច |
| ក្រុមការងារ«ង» | ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ |
| ក្រុមការងារ«ច» | ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ |
| ក្រុមការងារ«ឆ» | ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម |
| ក្រុមការងារ«ជ» | ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ |
| ក្រុមការងារ«ឈ» | ក្រុមការងារផ្នែកស្រូវអង្ករ |
| ក្រុមការងារ«ញ» | ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ |
| ក្រុមការងារ«ដ» | ក្រុមការងារផ្នែកអប់រំ |
| ក្រុមការងារ«ឋ» | ក្រុមការងារផ្នែកសុខាភិបាល |
| ក្រុមការងារ«ឌ» | ក្រុមការងារផ្នែកសំណង់និងអចលនទ្រព្យ |
| ក្រុមការងារ«ឍ» | ក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ |
| ក្រុមការងារ«ណ» | ក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍ |
| ក្រុមការងារ«ត» | ក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| គ.ស.រ.ជ. | គណៈកម្មាធិការសម្របសម្រួលការងារសម្រាប់យន្តការវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន |
| ន.ទ.ក. | និយ័តករទូរគមនាគមន៍កម្ពុជា |

## បញ្ជីពាក្យកាត់សំខាន់ៗជាអក្សរឡាតាំង

| | | |
|---|---|---|
| AI | Artificial Intelligence | បញ្ញាសិប្បនិម្មិត |
| CamPORS | Cambodia Pharmaceutical Online Registration System | ប្រព័ន្ធចុះទិដ្ឋាការ បញ្ជិកាផលិតផលឱសថតាមប្រព័ន្ធអនឡាញកម្ពុជា |
| G-PSF | Government-Private Sector Forum | វេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន |
| IoTs | Internet of Things | អ៊ីនធឺណិតនៃវត្ថុ |
| MIS | Management Information System | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| SOP | Standard Operating Procedure | នីតិវិធីប្រតិបត្តិស្តង់ដា |

# បរិសិដ្ឋ

# បរិសិដ្ឋទី១
# វិធីសាស្ត្រតាមដាន

ក្នុងការរៀបចំរបាយការណ៍វឌ្ឍនភាពសម្រាប់ឆមាសទី២ ឆ្នាំ២០២៥នេះ ប្រព័ន្ធតាមដាននិងវាយតម្លៃត្រូវបានកែលម្អ ក្នុងគោលបំណងធ្វើឱ្យប្រព័ន្ធនេះមានភាពបត់បែន ផ្តល់តម្លៃបន្ថែមដល់ការវិភាគនិងរៀបចំរបាយការណ៍ ព្រមទាំងពង្រីកវិសាលភាពនៃការតាមដាននិងវាយតម្លៃ ទៅគ្របដណ្តប់បញ្ហាប្រឈមដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ។ ដូចគ្នាទៅនឹងរបាយការណ៍វឌ្ឍនភាពឆមាសមុនៗដែរ របាយការណ៍វឌ្ឍនភាពនេះ ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ ផ្អែកលើលទ្ធផលប្រព័ន្ធតាមដានការអនុវត្តវិធានការវេទិកាG-PSF(វេទិកាG-PSF Tracking System) ដែលជាកិច្ចសហការរៀបចំរវាងក.អ.ក.និងរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍប្រកបដោយភាពធន់(CAPRED)។ ប្រព័ន្ធតាមដាននេះ មានឧបករណ៍សំខាន់ៗចំនួន២ រួមមានផ្ទាំងវិភាគទិន្នន័យ(Dashboard) និងតារាងបណ្តុំទិន្នន័យ(Dataset)។

ផ្ទាំងវិភាគទិន្នន័យ(Dashboard) គឺជាឧបករណ៍ដែលបង្ហាញពីវឌ្ឍនភាពបែបបរិមាណវិស័យនៃការអនុវត្តវិធានការក្នុងទម្រង់ជាក្រាហ្វិកព័ត៌មាន(Infographics)។ ផ្ទាំងវិភាគទិន្នន័យនេះត្រូវបានពង្រីកវិសាលភាព ដោយបានបែងចែកជា៤ផ្ទាំងផ្សេងគ្នា។ ផ្ទាំងវិភាគទិន្នន័យទី១ បង្ហាញពីវឌ្ឍនភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញក្នុងវេទិកាG-PSFលើកទី១៩ ដែលវឌ្ឍនភាពនេះត្រូវបានកំណត់ដោយកម្រិតចំនួន៣ គឺសម្រេចបានពេញលេញ(ពណ៌បៃតង) កំពុងត្រូវបានអនុវត្ត(ពណ៌ទឹកក្រូច) និងមិនទាន់ត្រូវបានអនុវត្ត(ពណ៌ក្រហម)។ ជាមួយគ្នានេះ ដើម្បីតាមដានពីស្ថានភាពនៃវិធានការដែលកំពុងត្រូវបានអនុវត្ត(ពណ៌ទឹកក្រូច) ពណ៌ចំនួន៣ទៀតត្រូវបានប្រើប្រាស់ គឺពណ៌ទឹកក្រូចខ្ចី សំដៅដល់ការសម្រេចបានពេញលេញនៃបង្គោលចរទី១ ដែលបង្ហាញថាវិធានការត្រូវបានចាប់ផ្តើមអនុវត្ត ពណ៌ទឹកក្រូចចាស់បន្តិច សំដៅដល់ការសម្រេចបានពេញលេញនៃបង្គោលចរទី២ដែលបង្ហាញថាវិធានការសម្រេចបានវឌ្ឍនភាពសំខាន់ និងពណ៌ត្នោតសំដៅដល់ការសម្រេចបានពេញលេញនៃបង្គោលចរទី៣ដែលបង្ហាញថាវិធានការបានបញ្ចប់ការអនុវត្ត ប៉ុន្តែពុំទាន់មានឯកសារយោងគ្រប់គ្រាន់នៅឡើយ។ ដោយឡែក ផ្ទាំងវិភាគទិន្នន័យទី២ ទី៣ និងទី៤ បង្ហាញពីវឌ្ឍនភាពនៃការដោះស្រាយបញ្ហាដែលលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យក្រោយវេទិកាG-PSFលើកទី១៩ ក្នុងឆ្នាំ២០២៤ ឆមាសទី១ និងឆមាសទី២ ឆ្នាំ២០២៥រៀងគ្នា ដែលវឌ្ឍនភាពនៃដំណោះស្រាយបញ្ហាត្រូវបានកំណត់ដោយកម្រិតចំនួន៣ដូចគ្នា គឺបានដោះស្រាយ(ពណ៌បៃតង) កំពុងដោះស្រាយ(ពណ៌ទឹកក្រូច) និងមិនទាន់ដោះស្រាយ(ពណ៌ក្រហម)។

តារាងបណ្តុំទិន្នន័យ(Dataset) គឺជាឧបករណ៍ផ្ទុកទិន្នន័យនិងព័ត៌មានសំខាន់ៗ ក្នុងទម្រង់ជាតារាងម៉ាទ្រីស ប្រមូលផ្តុំទៅដោយវិធានការដែលត្រូវបានបែងចែកទៅតាមក្រុមវិធានការ(ដូចមានចែងក្នុងសេចក្តីជូនដំណឹងលេខ១២៧២ សជណ.អកទ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីលទ្ធផលនៃវេទិកា

G-PSFលើកទី១៩ បញ្ហាប្រឈមដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ ក្រោយវេទិកា G-PSFលើកទី១៩ និងធាតុផ្សំសំខាន់ៗដទៃទៀត ដូចជាក្រុមវិធានការ ក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំអនុវត្ត ក្រសួង ស្ថាប័នគាំទ្រ កាលបរិច្ឆេទនៃកិច្ចប្រជុំក្រុមការងារតាមវិស័យ វឌ្ឍនភាព(ជារួមនិងតាមត្រីមាស) លទ្ធផលនៃការអនុវត្ត បញ្ហាប្រឈមក្នុងការអនុវត្ត សំណូមពរ ឯកសារយោងជាដើម។ វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ឬក្រុមវិធានការ ដែលបានដាក់ចេញក្នុងវេទិកាលើកទី១៩ សរុបមានចំនួន ១១ និងត្រូវបានបំបែកជាវិធានការលម្អិតតូចៗចំនួន១៧៩។ សនិទានភាពនៃការបំបែកវិធានការទាំងអស់ជាវិធានការលម្អិតតូចៗ ដោយសារវិធានការមួយចំនួនមានវិសាលភាពធំទូលាយនិងមានចរិតលក្ខណៈពហុបំណង ពោលគឺមានគោលបំណង២ឬ៣ ក្នុងវិធានការតែមួយ ដែលធ្វើឱ្យមានការលំបាកក្នុងការវាស់វែងវឌ្ឍនភាព និងអាចធ្វើឱ្យការតាមដានពុំសូវមានសុក្រឹតភាព។

ក្នុងការប្រមូលទិន្នន័យ ទម្រង់គំរូរបាយការណ៍ចំនួន២ ត្រូវបានរៀបចំដើម្បីអនុញ្ញាតឱ្យក្រសួង ស្ថាប័នទទួលបន្ទុកដឹកនាំអនុវត្ត បំពេញវឌ្ឍនភាពនៃការអនុវត្តវិធានការដែលបានដាក់ចេញក្នុងវេទិកា G-PSF និងបញ្ហាប្រឈមដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យក្រោយវេទិកាG-PSF។ ចំពោះទម្រង់គំរូរបាយការណ៍សម្រាប់វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ បង្គោលចរចំនួន៣ ត្រូវបានបង្កើតឡើងសម្រាប់វិធានការកំពុងអនុវត្តនីមួយៗ ដើម្បីតាមដានពីស្ថានភាពនៃវិធានការដែលកំពុងត្រូវបានអនុវត្ត។ បង្គោលចរចំនួន៣នេះ មានភាពខុសគ្នាទៅតាមវិធានការនីមួយៗ ប៉ុន្តែមានចរិតលក្ខណៈរួម គឺបង្គោលចរទី១បង្ហាញថា តើវិធានការនោះត្រូវបានចាប់ផ្តើមអនុវត្តហើយឬនៅ(Substantial beginning) បង្គោលចរទី២បង្ហាញថា តើវិធានការនោះសម្រេចបានវឌ្ឍនភាពសំខាន់ហើយឬនៅ(Substantial progress) និងបង្គោលចរទី៣បង្ហាញថា តើវិធានការនោះត្រូវបានបញ្ចប់ការអនុវត្តហើយឬនៅ(Finished point)។ ចំពោះទម្រង់គំរូរបាយការណ៍សម្រាប់បញ្ហាប្រឈម ដែលបានលើកឡើងនៅក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ ក្រសួង ស្ថាប័ន ត្រូវបំពេញព័ត៌មានពាក់ព័ន្ធនឹងបញ្ហាដែលបានលើកឡើង ការពិពណ៌នាពីបញ្ហា ការពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ ស្ថានភាពនៃវឌ្ឍនភាព ដែលមានចំនួន៣កម្រិត គឺបានដោះស្រាយ កំពុងដោះស្រាយ និងមិនទាន់ដោះស្រាយបញ្ហាប្រឈម សំណូមពរ និងឯកសារយោង។

បន្ថែមលើឧបករណ៍ខាងលើ ការស្ទង់មតិមួយត្រូវបានរៀបចំឡើងនៅក្នុងពិធីផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ក្នុងឆមាសទី១ ឆ្នាំ២០២៥ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២៥។ ការស្ទង់មតិនេះមានគោលបំណងប្រមូលធាតុចូលបឋមនិងរួមបញ្ចូលមតិឆ្លុះបញ្ចាំងព្រមទាំងការយល់ឃើញលើផលជះនៃការដាក់ចេញ និងការអនុវត្តវិធានការនៃវេទិកាG-PSFលើកទី១៩ ប្រសិទ្ធភាពក្រុមការងារតាមវិស័យ និងដំណើរការនៃវេទិកាG-PSF ពីវិស័យឯកជននិងក្រសួង ស្ថាប័នពាក់ព័ន្ធ។ ប៉ុន្តែផ្ទុយពីមុន របាយការណ៍ឆមាសនេះ ពុំបានរំលេចនូវផ្នែកការវាយតម្លៃលើការស្ទង់មតិផ្នែកឯកជនដូចរបាយការណ៍ឆមាសមុនៗឡើយ ដោយសារអ្នកចូលរួមស្ទង់មតិមានចំនួនត្រឹមតែ៤រូបប៉ុណ្ណោះ ធ្វើឱ្យការវិភាគលទ្ធផលនៃការស្ទង់មតិនេះពុំអាចប្រើប្រាស់ក្នុងការឆ្លុះបញ្ចាំងទស្សនៈយល់ឃើញរបស់ផ្នែកឯកជន។

ក្នុងការងារធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ វេទិកាG-PSF Tracking System ក.អ.ក.បាននិងកំពុងបន្តសហការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីCAPRED ដើម្បីបន្តពង្រឹងសមត្ថភាពរបស់ប្រព័ន្ធតាមដាននិងវាយតម្លៃផង និងរៀបចំថ្នាលគ្រប់គ្រងព័ត៌មានវិទ្យា(MIS) សម្រាប់ការងារតាមដាននិងវាយតម្លៃនេះផងដែរ។

# បរិសិដ្ឋទី២

## តារាងវឌ្ឍនភាព[២] នៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញ ក្នុងវេទិកាG-PSF លើកទី១៩ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួងស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| **១- ការកែសម្រួលបរិយាកាសធុរកិច្ចនិងការវិនិយោគ** | | | | | |
| ១.១- ការបំពេញកាតព្វកិច្ចគណនេយ្យ និងសវនកម្ម | | | | | |
| ១.១.៣- ប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដូចខាងក្រោម៖ | | | | | |
| ១ | ១.១.៣.ក- | ដឹកនាំធ្វើវិសោធនកម្មអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី២) | អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្មបានឆ្លងយន្តការ ដូចខាងក្រោម៖<br>- កិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទ អ.ស.ហ. លើកទី១ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ និងលើកទី២ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ ២០២៤ |

២ តារាងនេះបង្ហាញត្រឹមវឌ្ឍនភាពនៃការអនុវត្តវិធានការដែលនៅសេសសល់ពីឆមាសទី១ឆ្នាំ២០២៥ ចំណែកឯវឌ្ឍនភាពនៃវិធានការដែលបានសម្រេចរួចរាល់ចាប់ពីឆមាសទី១ ឆ្នាំ២០២៤ រហូតដល់ឆមាសទី១ ឆ្នាំ២០២៥ គឺមានរំលេចលម្អិតក្នុងរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ ប្រចាំឆមាសទី២ ឆ្នាំ២០២៤ និងប្រចាំឆមាសទី១ ឆ្នាំ២០២៥។

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួង ស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | | -កិច្ចប្រជុំរាយការណ៍អំពីវឌ្ឍនភាពនិងឆ្លងយោបល់ ឯកឧត្តម ងី តាយី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាសមាជិកក្រុមប្រឹក្សាអ.ស.ហ. នៅថ្ងៃទី៣ ខែ កញ្ញា ឆ្នាំ២០២៤<br>- កិច្ចប្រជុំក្រុមប្រឹក្សាអ.ស.ហ. លើកទី២០ អាណត្តិទី១ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤<br>- កិច្ចប្រជុំជំនាញបច្ចេកទេសជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន២លើក នៅថ្ងៃទី១៣ និងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៤ ស្របតាមស្មារតីកិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ.<br>- អនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម បានដាក់ឆ្លងយន្តការនៃទីស្តីការគណៈរដ្ឋមន្ត្រី រួមទាំងកិច្ចប្រជុំអន្តរក្រសួងនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៥ តាមស្មារតីនៃកិច្ចប្រជុំអន្តរ-ក្រសួង ន.គ.ស. និងក្រសួងយុត្តិធម៌ ត្រូវជួបពិភាក្សានិងផ្តល់យោបល់ផ្នែកទណ្ឌកម្មពិន័យ ប៉ុន្តែរហូតមកដល់ពេលនេះ ក្រសួងយុត្តិធម៌ពុំទាន់មានពេលវេលាអាចជួប ដើម្បីពិនិត្យនិងផ្តល់យោបល់ជូននៅឡើយទេ ។ |
| ២ | ១.១.៣.ក.១- | ដឹកនាំធ្វើវិសោធនកម្មប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត | ប្រកាសស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យបានឆ្លងយន្តការដូចខាងក្រោម៖ |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួងស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | (បង្គោលចរទី២) | - កិច្ចប្រជុំបច្ចេកទេសអង្គភាពក្រោមឱវាទអសហ លើកទី ១ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ និង លើកទី២ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៤<br>-កិច្ចប្រជុំរាយការណ៍អំពីវឌ្ឍនភាពនិងឆ្លងយោបល់ ឯកឧត្តម ងី តាយី រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាអសហ នៅថ្ងៃទី៣ ខែ កញ្ញា ឆ្នាំ២០២៤<br>- កិច្ចប្រជុំក្រុមប្រឹក្សាអសហ លើកទី២០ អាណត្តិទី១ នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤<br>- បានឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើទំហំដើមទុន និង ផលរបរជាមួយតំណាងសភាពាណិជ្ជកម្មកម្ពុជា នៅថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ២០២៤<br>-បានឆ្លងយន្តការពិភាក្សាពិគ្រោះយោបល់លើទំហំដើមទុននិងផលរបរជាមួយឯកឧត្តមបណ្ឌិត ផាន់ ផល្លា រដ្ឋលេខាធិការកសហវ និងជាអគ្គលេខាធិការនៃអគ្គ-លេខាធិការដ្ឋានគសហ កាលពីថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥ ស្របតាមស្មារតីនៃកិច្ចប្រជុំក្រុមប្រឹក្សាអសហរួចរាល់ ប៉ុន្តែត្រូវរង់ចាំអនុក្រឹត្យស្តីពីពិន័យអន្តរការណ៍ |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួង ស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | | ចំពោះអំពើល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្មចូលជាធរមាន ។ |
| ៣ | ១.១.៣.គ- | ជំរុញការរៀបចំសទ្ទានុក្រមវាក្យសព្ទគណនេយ្យនិងសវនកម្ម ព្រមទាំងការបកប្រែស្តង់ដាគណនេយ្យ និងសវនកម្មជាភាសាខ្មែរ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី២) | - បានចាប់ផ្តើមការរៀបចំសទ្ទានុក្រមវាក្យសព្ទគណនេយ្យនិងសវនកម្មព្រមទាំងការបកប្រែស្តង់ដាគណនេយ្យនិងសវនកម្មជាភាសាខ្មែរ<br>- បានឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាអសហ អាណត្តិទី១ លើកទី២០ កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ និងទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ដើម្បីដាក់ឱ្យអនុវត្តសទ្ទានុក្រមគណនេយ្យនិងសវនកម្ម កម្មវិធីទូរសព្ទវៃឆ្លាត សទ្ទានុ-ក្រមគណនេយ្យនិងសវនកម្ម និងបោះពុម្ពផ្សព្វផ្សាយសទ្ទានុក្រមគណនេយ្យនិងសវនកម្ម កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៤។<br>- សទ្ទានុក្រមគណនេយ្យនិងសវនកម្ម ត្រូវបានបោះពុម្ពនិងបានដាក់ឱ្យប្រើប្រាស់ក្នុងកម្មវិធីវេទិកាជាតិគណនេយ្យឆ្នាំ២០២៥ កាលពីថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៥ ។<br>-ក្រុមការងារបច្ចេកទេសរៀបចំនិងបកប្រែស្តង់ដាគណនេយ្យស្តង់ដាសវនកម្មនិងស្តង់ដាពាក់ព័ន្ធជា |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួងស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | | ភាសាខ្មែរ ត្រូវបានបង្កើតឡើង និងត្រៀមរៀបចំការបកប្រែក្នុងឆ្នាំ២០២៦។ |
| ៤ | ១.៦- | ការពិនិត្យលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណឡើងវិញប្រគល់ភារកិច្ចជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្របសម្រួល និងដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ធ្វើការពិនិត្យឡើងវិញនូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណទាំងអស់ ក្នុងវិស័យនីមួយៗ ដោយចាប់ផ្ដើមពីវិស័យទេសចរណ៍និងវិស័យសហគ្រាសធុនមីក្រូ តូច និងមធ្យម ដើម្បីលុបចេញឬផ្គួបចូលគ្នានូវលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណដែលត្រួតស៊ីគ្នា ព្រមទាំងកែសម្រួលនីតិវិធីនិងថ្លៃសេវានៃលិខិតអនុញ្ញាតនិងអាជ្ញាបណ្ណនីមួយៗ ឱ្យមានភាពច្បាស់លាស់ពោលគឺធ្វើយ៉ាងណាធានាថាគ្មាននីតិវិធីមួយណាដែលបង្កការលំបាកនិងដែលមិនចាំបាច់ដល់ប្រជាពលរដ្ឋឡើយ។ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី២) | លេខាធិការដ្ឋានក្រុមការងាររៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច បានដាក់ឱ្យអនុវត្តនូវ«យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨» កាលពីខែមេសា ឆ្នាំ២០២៥ កន្លងមក ដោយគោលដៅ១ ក្នុងចំណោមគោលដៅទាំង៤ ដែលត្រូវអនុវត្តក្នុងយុទ្ធសាស្ត្រនេះ គឺស្របទៅតាមវិធានការ១.៦ នៃវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី១៩។ ជាវឌ្ឍនភាព លេខាធិការដ្ឋានក្រុមការងាររៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច បាននិងកំពុងរៀបចំ«ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ២០២៥-២០២៨»។ ជាមួយនេះ លេខាធិការដ្ឋាន បាននិងកំពុងធ្វើការជាមួយក្រសួងស្ថាប័នមួយចំនួន ដូចជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធ្វើឌីជីថលូបនីយកម្ម |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួង ស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | | សេវាពាក់ព័ន្ធធុរកិច្ច អមជាមួយនឹងការពិនិត្យនិងកែសម្រួលនីតិវិធី និងថ្លៃនៃការផ្ដល់សេវារបស់ក្រសួងស្ថាប័នខាងលើផងដែរ។ |
| **៥- ការលើកកម្ពស់ការដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ** | | | | | |
| ៥ | ៥- | ប្រគល់ភារកិច្ចជូន ឯកឧត្តម **ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ធ្វើវិសោធនកម្មច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងសិក្សាពីបច្ចេកទេសឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីកំណត់ប្រភេទរថយន្តនិងប្រភេទផ្លូវ ដែលអាចប្រើប្រាស់បានសម្រាប់ការដំឡើងកម្រិតទម្ងន់រថយន្តដឹកទំនិញពី៤០តោនទៅដល់៤៥តោន | ក្រសួងសាធារណ-ការនិងដឹកជញ្ជូន | កំពុងត្រូវបានអនុវត្ត (បង្គោលចរ ទី២) | គ.១- សេចក្ដីព្រាងច្បាប់ស្ដីពី វិសោធនកម្មច្បាប់ស្ដីពីផ្លូវថ្នល់ ត្រូវបានដាក់ឆ្លងប្រជុំពិនិត្យនិងពិភាក្សានៅទីស្ដីការគណៈរដ្ឋមន្ត្រី ចំនួន៣លើករួចហើយ រួមមានលើកទី១: ប្រជុំជំនាញបច្ចេកទេស កាលពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២៥ លើកទី២ : កិច្ចប្រជុំអន្តរក្រសួង ចង្អៀត កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៥ និងលើកទី៣ : កិច្ចប្រជុំអន្តរក្រសួង កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ (ជាលទ្ធផល សេចក្ដីព្រាងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីផ្លូវថ្នល់ឆ្នាំ២០១៤ ត្រូវធ្វើវិសោធនកម្មចំនួន៦មាត្រា រួមមានមាត្រា២៥និងមាត្រា២៦នៃជំពូកទី៦ មាត្រា៤៣ នៃជំពូកទី១០ និងមាត្រា៥០ មាត្រា៦០ និងមាត្រា ៦១នៃជំពូកទី១១)។<br>គ.២- ទីស្ដីការគណៈរដ្ឋមន្ត្រី បានស្នើក្រសួងយុត្តិធម៌ ជួយពិនិត្យនិងផ្ដល់យោបល់លើខ្លឹមសារនៃមាត្រាពាក់ព័ន្ធនឹង |

| ល.រ. | លេខរៀង វិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួង ស្ថាប័នសម្រេចបានសម្រាប់វិធានការដែល កំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | | ទោសប្បញ្ញត្តិសម្រាប់ «សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីផ្លូវថ្នល់»។<br>គ.៣- ក្រសួងសាធារណការនិងដឹកជញ្ជូន បានរៀបចំកិច្ចប្រជុំ ជាមួយក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ ផ្តល់យោបល់និងកែសម្រួលខ្លឹមសារនៃ«សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីផ្លូវថ្នល់» លើមាត្រាដែលពាក់ព័ន្ធនឹងទោសប្បញ្ញត្តិ។ ជារួម ក្រសួងយុត្តិធម៌បានឯកភាពលើសំណើសុំធ្វើវិសោធនកម្ម មាត្រាពាក់ព័ន្ធនឹងទោសប្បញ្ញត្តិ សម្រាប់សេចក្តីព្រាងច្បាប់នេះ។ |
| **៦- ការស្តារនិងការលើកស្ទួយការអភិវឌ្ឍវិស័យទេសចរណ៍** | | | | | |
| ៦.២- ជំរុញអនុវត្តកម្មវិធីពិសេស «ទស្សនាសៀមរាប ឆ្នាំ២០២៤» តាមរយៈវិធានការមួយចំនួនទៀតដូចខាងក្រោម៖ | | | | | |
| ៦ | ៦.២.២- | ទី២- ការពង្រីកវិសាលភាពបណ្តុំព្រំដែន ប្រគល់ភារកិច្ចជូន ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម **សុខ ចិន្តាសោភា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សហការរៀបចំនិងជំរុញការងារការចរចាកែសម្រួលកិច្ចព្រមព្រៀងឆ្លងព្រំដែន ដោយពង្រីកវិសាលភាពបណ្តុំព្រំដែននេះឱ្យបានឆាប់ | ក្រសួងមហាផ្ទៃ និង ក្រសួងការបរទេស និង សហប្រតិបត្តិការ អន្តរជាតិ | បានសម្រេចពេញលេញ | |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួងស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| ៧ | ៦.២.៤- | ប្រគល់ភារកិច្ចជូនធនាគារសហគ្រាសធុនតូចនិងមធ្យមកម្ពុជា រៀបចំជាកម្មវិធីផ្ដល់កម្ចីដោយផ្ទាល់ជាមួយនឹងទឹកប្រាក់បឋមចំនួន៥០លានដុល្លារអាមេរិក ដល់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប ជាមួយនឹងអត្រាការប្រាក់សមរម្យនិងលក្ខខណ្ឌអនុគ្រោះផ្សេងទៀត ដើម្បីអនុញ្ញាតឱ្យប្រតិបត្តិករទេសចរណ៍អាចទទួលបាននូវហិរញ្ញប្បទានក្នុងចំនួនទឹកប្រាក់សមស្របតាមប្រភេទអាជីវកម្ម | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | បានសម្រេចពេញលេញ | |
| ៦.៣- បន្តដោះស្រាយបញ្ហាប្រឈមក្នុងវិស័យទេសចរណ៍ផ្សេងទៀត តាមរយៈវិធានការដូចខាងក្រោម៖ | | | | | |
| ៦.៣.៤- ទី៣- បញ្ហាប្រឈមនិងសំណូមពរ ដែលត្រូវការដំណោះស្រាយក្នុងរយៈពេលមធ្យម<br>ប្រគល់ភារកិច្ចជូន ឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ធ្វើការសិក្សាលទ្ធភាពអនុវត្តលើសំណើសុំពាក់ព័ន្ធនឹង៖ | | | | | |
| ៨ | ៦.៣.៤.១- | ការបង្កើតខ្សែក្រវាត់បៃតងនៅតាមតំបន់ទេសចរណ៍សំខាន់ៗ ដើម្បីជំរុញការផ្គត់ផ្គង់បន្លែសាច់របស់ប្រជាកសិករដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី២) | (វឌ្ឍនភាពឆមាសទី១ ២០២៥)<br>-បានបង្កើតក្រុមការងារសិក្សានិងជំរុញការអនុវត្តវិធានការបង្កើតខ្សែក្រវាត់បៃតងនៅតំបន់ទេសចរណ៍សំខាន់ៗ<br>-កំពុងរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងទេសចរណ៍ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>(រក្សាវឌ្ឍនភាពឆមាសទី២ ២០២៥ ដូចឆមាសមុន) |
| ៩ | ៦.៣.៤.២- | ការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ | ក្រសួងទេសចរណ៍ | កំពុងត្រូវបានអនុវត្ត | -បានបង្កើតក្រុមការងារសិក្សានិងជំរុញការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួងស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | (បង្គោលចរទី២) | -បានរៀបចំផែនការសកម្មភាពជំរុញការអភិវឌ្ឍភ្នំគូលែនជាគោលដៅទេសចរណ៍ធម្មជាតិ<br>-កំពុងរៀបចំអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងទេសចរណ៍និងក្រសួងបរិស្ថាន |
| **៧- ការអភិវឌ្ឍវិស័យកសិកម្មនិងកសិឧស្សាហកម្ម** | | | | | |
| ១០ | ៧.៣- | ពន្លឿនការរៀបចំច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា ដើម្បីបង្កើនទំនុកចិត្តរវាងកសិករនិងក្រុមហ៊ុនប្រមូលទិញ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី២) | - បង្គោលចរទី១: បានប្រជុំចំនួន២៣លើក និងបានពិនិត្យកែសម្រួលសម្រេចមានចំនួន១៣ជំពូក និង៧១មាត្រា។<br>-បង្គោលចរទី២: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងពិនិត្យលទ្ធភាពរៀបចំសិក្ខាសាលាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធលើទិដ្ឋភាព ដូចខាងក្រោម៖<br>- ទិដ្ឋភាពគតិយុត្ត<br>-យន្តការរបស់រាជរដ្ឋាភិបាលក្នុងការជួយគាំទ្រ និងសម្រប-សម្រួល។ |
| **១០- វិស័យសំណង់និងអចលនទ្រព្យ** | | | | | |
| ១១ | ១០.៤.២- | ការកំណត់លក្ខខណ្ឌវិនិច្ឆ័យជាក់លាក់ ក្នុងការផ្តល់ទិដ្ឋាការសម្រាប់ជនបរទេសទទួលសិទ្ធិអនុវត្តតាមយន្តការទាំង៤ខាងលើ ដែលនឹងត្រូវស្នើឡើងដោយក្រសួងមហាផ្ទៃ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី២) | បានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទនិងនីតិវិធីនៃការអនុញ្ញាតឱ្យជនបរទេស មិនមែនអន្តោប្រវេសន្តចូល ចេញ ឆ្លងកាត់ និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅខែកក្កដា ឆ្នាំ២០២៤ (ដឹកនាំដោយក្រសួងមហាផ្ទៃ |

| ល.រ. | លេខរៀង វិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួង ស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| | | | | | ដោយមានចូលរួមពីតំណាងក្រសួងដ.ន.ស. និងក្រសួង-ស្ថាប័នពាក់ព័ន្ធ)។ ក្រសួងមហាផ្ទៃ កំពុងបន្តរៀបចំ នីតិវិធីទៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| **១១- បញ្ហាផ្សេងៗ** | | | | | |
| ១២ | ១១.៣- | ប្រគល់ភារកិច្ចជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំ «កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង បង្កើនពិពិធកម្ម និងពង្រឹងភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ចនៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់» សម្រាប់រយៈពេល៤ឆ្នាំ ពីឆ្នាំ២០២៤ដល់ឆ្នាំ២០២៨ ដែលត្រូវរួមបញ្ចូលផងដែរនូវការគិតគូរដោះស្រាយបញ្ហាធំៗមួយចំនួន ដែលវិស័យឯកជនបានលើកឡើងមានជាអាទិ៍៖<br>ក- ការអភិវឌ្ឍធនធានមនុស្សនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ខ- ការជំរុញការអភិវឌ្ឍសហគ្រាសធុនមីក្រូ តូច និងមធ្យម | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | បានសម្រេចពេញលេញ | |

| ល.រ. | លេខរៀង វិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័ន ទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួង ស្ថាប័នសម្រេចបានសម្រាប់វិធានការដែល កំពុងអនុវត្ត |
|---|---|---|---|---|---|
| | | គ- ការបង្កើនភាពទាក់ទាញសម្រាប់ការវិនិយោគផ្ទាល់ពីបរទេស<br>ឃ- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង<br>ង- ការអនុវត្តផែនការមេអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង<br>ច- ការជំរុញការអភិវឌ្ឍវិស័យកសិកម្មនិងវិស័យទេសចរណ៍<br>ឆ- ការជំរុញការអភិវឌ្ឍឧស្សាហកម្មថ្មីៗ ដូចជាវិស័យយានយន្តនិងអេឡិចត្រូនិកកម្ពុជា ជាដើម<br>ជ- កិច្ចសម្រួលពាណិជ្ជកម្ម ជាពិសេសការជំរុញការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដើម្បីកាត់បន្ថយឱ្យអស់នូវការប្រើប្រាស់ឯកសារនាំចេញនាំចូលក្នុងទម្រង់រឹងឱ្យបានក្នុងរយៈពេល៤ឆ្នាំ<br>ឈ- ការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវដែកដែលមានបច្ចុប្បន្ន ឱ្យមានប្រសិទ្ធភាពនិងថ្លៃសមរម្យ<br>ញ- ការជំរុញការកែសម្រួលឱ្យកាន់តែមានភាពប្រកួតប្រជែងបន្ថែមទៀត នូវបរិយាកាសធុរកិច្ចនិងការវិនិយោគជាដើម | | | |

| ល.រ. | លេខរៀងវិធានការ | វិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដែលបានដាក់ចេញក្នុងវេទិកាG-PSF លើកទី១៩ | ក្រសួង ស្ថាប័នទទួលបន្ទុក | វឌ្ឍនភាព | វឌ្ឍនភាពដែលក្រសួងស្ថាប័នសម្រេចបានសម្រាប់វិធានការដែលកំពុងអនុវត្ត |
|---|---|---|---|---|---|
| ១៣ | ១១.៦- | ប្រគល់ភារកិច្ចជូន ឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី និងជាអនុប្រធានទី១ នៃក.អ.ក. រៀបចំវេទិកាG-PSF ឱ្យបានយ៉ាងហោច២លើក នៅក្នុងអាណត្តិនីមួយៗរបស់រាជរដ្ឋាភិបាល | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | កំពុងត្រូវបានអនុវត្ត (បង្គោលចរទី ២) | ១-បាននឹងកំពុងទាក់ទងជាមួយគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(គ.ស.ហ.វ.) ដើម្បីក្តាប់បាននូវបញ្ហាដែលត្រូវលើកក្នុងវេទិកាពេញអង្គ។ ២- បានធ្វើលិខិតទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីស្នើសុំការធ្វើបច្ចុប្បន្នភាពសមាសភាពតំណាងក្នុងក្រុមការងារទាំង១៦ ដោយដាក់ឱសានវាទត្រឹមដំណាច់ខែមករា ឆ្នាំ២០២៦។ បន្ទាប់ពីទទួលបានបច្ចុប្បន្នភាពសមាស-ភាពពីបណ្តាលក្រសួង ស្ថាប័នរួចហើយ ក.អ.ក.នឹងលើកសំណើសុំរាជរដ្ឋាភិបាលចេញសេចក្តីសម្រេចស្តីពីការកែសម្រួលនូវសមាសភាពតាមក្រុមការងារតាមវិស័យនេះ។ (ការធ្វើបច្ចុប្បន្នភាពភាពនេះ ជាកិច្ចការចាំបាច់មុនពេលត្រៀមរៀបចំវេទិការាជរដ្ឋាភិបាល លើកទី២០) |

## **ឧបសម្ព័ន្ធទី៣**

## **តារាងវឌ្ឍនភាពបញ្ហាប្រឈមនិងសំណូមពររបស់ផ្នែកឯកជនលើកឡើងក្នុងក្រុមការងារតាមវិស័យ ក្រោយវេទិកាG-PSF លើកទី១៩ គិតត្រឹមឆមាសទី២ ឆ្នាំ២០២៥**

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| **ក្រុមការងារផ្នែកទេសចរណ៍ (ក្រុម«ខ»)** | | | |
| ឆ្នាំ២០២៤ | | | |
| 1 | ការជំរុញការផ្សព្វផ្សាយទេសចរណ៍កម្ពុជាប្រកបដោយភាពត្រឹមត្រូវនិងច្បាស់លាស់ | ស្នើសុំរាជរដ្ឋាភិបាលមានយុទ្ធនាការផ្សព្វផ្សាយទេសចរណ៍កម្ពុជាមួយដែលប្រកបដោយភាពត្រឹមត្រូវនិងមានភាពច្បាស់លាស់។ | បានដោះស្រាយ |
| 2 | ការជំរុញកិច្ចសហការផ្សព្វផ្សាយទេសចរណ៍កម្ពុជាជាមួយវិស័យឯកជននិងក្រុមហ៊ុនផ្សព្វផ្សាយ | ស្នើសុំរាជរដ្ឋាភិបាលសហការជាមួយវិស័យឯកជន គ្រប់ការផ្សព្វផ្សាយពីផលិតផលទេសចរណ៍ ត្រូវមានពាក្យ «កម្ពុជា» និងសហការជាមួយខ្សែភាពយន្តអន្តរជាតិឱ្យមកថតនៅកម្ពុជា និងបង្ហាញអត្តសញ្ញាណកម្ពុជាឱ្យគេស្គាល់ ព្រមទាំងរៀបចំកញ្ចប់ថវិកាធំមួយដើម្បីផ្សព្វផ្សាយតាមគ្រប់មធ្យោបាយ ជារៀងរាល់ឆ្នាំ និងជួលអ្នកជំនាញទីផ្សារអន្តរជាតិផងដែរ។ | បានដោះស្រាយ |
| 3 | ការកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យទេសចរណ៍ | ស្នើឱ្យរដ្ឋាភិបាលផ្តល់ជំនួយបន្ថែម/ការលើកទឹកចិត្ត និងកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់បុគ្គលិកបម្រើការក្នុងវិស័យទេសចរណ៍។ | កំពុងដោះស្រាយ |
| 4 | មគ្គុទេសក៍ទេសចរណ៍ភាគច្រើនបានទិញផ្ទះក្នុងបុរីបង់រំលោះ ប្រឈមនឹងការផាកពិន័យឬការយកវិញពីម្ចាស់បុរី | ស្នើសុំរាជរដ្ឋាភិបាលធ្វើការសម្របសម្រួលលើកម្ចីទិញផ្ទះក្នុងវិស័យទេសចរណ៍ ដោយចេញវិធានការណាមួយ ដូចជាការពន្យារពេលការបង់ប្រាក់កម្ចីជាដើម។ អង្គប្រជុំស្នើលើកបញ្ហានេះជូនក្រុមការងារផ្នែកសំណង់និងអចលនទ្រព្យ(ក្រុម«ឌ»)។ | កំពុងដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| **ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច (ក្រុម«ឃ»)** | | | |
| ឆ្នាំ២០២៤ | | | |
| 1 | ពន្ធនាំចេញលើការប្រមូលរ៉ែទង់ដែង(២៥%លើតម្លៃលក់ បូកបន្ថែមនឹងថ្លៃដឹកជញ្ជូន) ធ្វើឱ្យអាជីវកម្មរុករករ៉ែទង់ដែងមិនទទួលបានប្រាក់ចំណេញ | វិស័យឯកជនស្នើឱ្យរាជរដ្ឋាភិបាលកម្ពុជាកាត់បន្ថយពន្ធនាំចេញ កំហាប់រ៉ែទង់ដែងពី២៥% មកត្រឹម០% លើតម្លៃលក់ បូកនឹងថ្លៃដឹកជញ្ជូន ដើម្បីឱ្យការជីកយករ៉ែទង់ដែង អាចមានប្រាក់ចំណេញ ដោយបច្ចុប្បន្ននេះរាជរដ្ឋាភិបាលកំណត់យកសួយសារ៦%លើការផលិតដុំរ៉ែទង់ដែង និងពន្ធ៣០%លើប្រាក់ចំណេញបន្ថែមពីលើពន្ធនាំចេញ។ | កំពុងដោះស្រាយ |
| **ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ (ក្រុម«ខ»)** | | | |
| ឆ្នាំ២០២៤ | | | |
| 1 | បញ្ហាសន្តិសុខសាយប័រ | ស្នើធនាគារជាតិនៃកម្ពុជា ចូលរួមសម្របសម្រួលជាមួយក្រសួងយុត្តិធម៌ ដើម្បីបញ្ជាក់ឬបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់ការបង្កប្រតិបត្តិការធនាគារនិងការចែករំលែកព័ត៌មាន(គណនីប្រតិបត្តិការនិងអង្គភាពពាក់ព័ន្ធ)។ | កំពុងដោះស្រាយ |
| 2 | នីតិវិធីដោះស្រាយបណ្ដឹង | សមាគមធនាគារនៅកម្ពុជានឹងជួបជាមួយក្រសួងយុត្តិធម៌ ដើម្បីដោះស្រាយបណ្ដឹងរបស់សមាជិក និងស្នើសុំជំនួយបន្ថែមពីធនាគារជាតិនៃកម្ពុជា។ | កំពុងដោះស្រាយ |
| **ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ (ក្រុម«ច»)** | | | |
| ឆ្នាំ២០២៤ | | | |
| 1 | ការមិនបានប្រគល់រថយន្តមកឱ្យខាងក្រុមហ៊ុន ដើម្បីប្រកបអាជីវកម្មវិញឡើយ ក្នុងករណីគ្រោះថ្នាក់មិនដល់អាយុជីវិត | សុំការអនុញ្ញាតឱ្យអាចយកយានយន្តមកប្រកបអាជីវកម្មបានវិញ នៅពេលក្រុមហ៊ុនជួបគ្រោះថ្នាក់ចរាចរណ៍(មិនដល់ជីវិត)។ | កំពុងដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| **ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញនិងកិច្ចសម្រួលពាណិជ្ជកម្ម ( ក្រុម«ឆ» )** | | | |
| ឆមាសទី២ ឆ្នាំ២០២៥ | | | |
| 1 | ការចូលរួមតាំងពិព័រណ៍ផលិតផលខ្មែរនៅបរទេស | ស្នើសុំក្រសួងពាណិជ្ជកម្មជួយសម្របសម្រួលជាមួយដៃគូពាណិជ្ជកម្មអន្តរជាតិ ក្នុងការទទួលបាននូវប្រតិទិនឬកាលបរិច្ឆេទ នៃការតាំងពិព័រណ៍អន្តរជាតិប្រចាំឆ្នាំ និងនីតិវិធីក្នុងការស្នើសុំចូលរួមតាំងពិព័រណ៍ ដើម្បីឱ្យវិស័យឯកជនមានឱកាសក្នុងការនាំយកផលិតផលខ្មែរតាំងបង្ហាញក្នុងពិព័រណ៍អន្តរជាតិ និងជំរុញផលិតផលខ្មែរទៅកាន់ទីផ្សារអន្តរជាតិកាន់តែទូលំទូលាយ។ | បានដោះស្រាយ |
| **ក្រុមការងារផ្នែកស្រូវអង្ករ ( ក្រុម«ឈ» )** | | | |
| ឆមាសទី២ ឆ្នាំ២០២៥ | | | |
| 1 | បញ្ចៀសការធ្លាក់ចុះតម្លៃស្រូវផ្ការំដួល | ១) រកវិធានការទប់ស្កាត់ការធ្លាក់ចុះតម្លៃស្រូវផ្ការំដួល។<br>២) កំណត់បរិមាណស្រូវតាមប្រភេទពូជនីមួយៗឱ្យបានច្បាស់ក្នុងតំបន់នីមួយៗ ដើម្បីឱ្យវិស័យឯកជនងាយចុះជួយអន្តរាគមន៍ក្នុងពេលប្រមូលផល។<br>៣) រៀបចំស្តង់ដាអង្ករផ្ការំដួល និងសែនក្រអូបរបស់កម្ពុជាឱ្យស្រប តាមលក្ខណសម្បត្តិនិងគុណភាពពិសេសរបស់ពូជទាំងពីរ។ | បានដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
| --- | --- | --- | --- |
| **ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ** ( **ក្រុម«ញ»** ) | | | |
| ឆមាសទី១ ឆ្នាំ២០២៥ | | | |
| 1 | ពន្ធលើសន្និធិពាណិជ្ជកម្មប្រេងនិងឧស្ម័នឥន្ធនៈ | ស្នើសុំកុំទាន់យកពន្ធអាករសម្រាប់បរិមាណប្រេងនិងឧស្ម័នឥន្ធនៈ ដែលជាសន្និធិពាណិជ្ជកម្ម ដោយស្នើសុំបង់ពន្ធនៅពេលបញ្ចេញលក់។ | កំពុងដោះស្រាយ |
| 2 | ពន្ធលើប្រេងយន្តហោះ | ស្នើសុំសូមឱ្យលើកលែងពន្ធសម្រាប់ប្រេងយន្តហោះ ដូចជាអាករពិសេស និងអាករលើតម្លៃបន្ថែម ដើម្បីជួយជំរុញលើវិស័យទេសចរណ៍។ | កំពុងដោះស្រាយ |
| 3 | ការរត់គេចពន្ធនាំចូលប្រេងនិងឧស្ម័នឥន្ធនៈ | សំណូមពរឱ្យស្ថាប័នពាក់ព័ន្ធជួយពង្រឹងនិងមានវិធានការលើការរត់គេចពន្ធប្រេងនិងឧស្ម័នឥន្ធនៈទាំងនេះ។ | កំពុងដោះស្រាយ |
| 4 | ការកំណត់ថ្លៃលក់រាយប្រេងសាំង | ស្នើសុំពិនិត្យលើការគណនាថ្លៃប្រេងសាំងលក់រាយឡើងវិញ ដោយប្រើប្រាស់តម្លៃមធ្យមភាគនៃផលិតផលប្រេងឥន្ធនៈលក់ដុំនៅប្រទេសសិង្ហបុរី( Mean of Platts Singapore-MOPS ) នៃប្រេងសាំង ដែលមានបរិមាណស៊ុលហ្វួ១0PPM ឬប្រហាក់ប្រហែល។ | កំពុងដោះស្រាយ |
| 5 | ការបញ្ចុះថ្លៃលក់រាយប្រេងសាំងនិងម៉ាស៊ូតចំនួន ១សេន/លីត្រ របស់ក្រុមហ៊ុនប្រេងឥន្ធនៈ | ស្នើសុំលុបចោលការបញ្ចុះថ្លៃប្រេងសាំងនិងម៉ាស៊ូត១សេន/លីត្រវិញ ដែលធ្លាប់បានអនុវត្តកន្លងមក។ | កំពុងដោះស្រាយ |
| 6 | សេវាសាធារណៈសម្រាប់ការអនុញ្ញាតសាងសង់ស្ថានីយប្រេងនិងឧស្ម័នឥន្ធនៈ | ស្នើសុំបន្ធូរបន្ថយកម្រៃសេវាសម្រាប់ស្ថានីយចាស់ៗ ដោយកំណត់ទៅតាមទំហំស្ថានីយតូចឬធំ នៅជនបទឬនៅទីក្រុង។ | កំពុងដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| **ក្រុមការងារផ្នែកសុខាភិបាល** (**ក្រុម«ថ»**) | | | |
| ឆ្នាំ២០២៤ | | | |
| 1 | ផលវិបាកក្នុងវិស័យមន្ទីរពិសោធន៍ដែលបានពិភាក្សាក្នុងកិច្ចប្រជុំជាមួយក្រសួងសុខាភិបាល កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ | ស្នើក្រសួងគួរបង្កើតក្រុមប្រឹក្សាវិជ្ជាជីវៈមួយ ជាពិសេសលើឯកទេសគ្រប់គ្រងមន្ទីរពិសោធន៍ ដែលបានពិភាក្សាគ្នាក្នុងកិច្ចប្រជុំកាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣។ ផ្នែកឯកជនស្នើសុំចម្លើយលើវឌ្ឍនភាពលើបញ្ហានេះ។ | កំពុងដោះស្រាយ |
| 2 | ការកំណត់ថ្លៃសេវាសម្រាប់ការស្នើសុំការផ្លាស់ប្តូរ | ស្នើសុំចម្លើយវឌ្ឍនភាពលើបញ្ហានេះ។ | កំពុងដោះស្រាយ |
| ឆមាសទី១ ឆ្នាំ២០២៥ | | | |
| 1 | វិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ(Health Certificate of Food Products) | ស្នើសុំបន្ថែមសុពលភាពវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហាររហូតដល់៣ឆ្នាំ។ | កំពុងដោះស្រាយ |
| 2 | សេចក្តីជូនដំណឹង(លេខ ៦៨១៨ អបស/ឱអបស) មិនអនុញ្ញាតឱ្យចុះបញ្ជិកាឱសថ ដែលផ្សំពីសារធាតុសកម្មស្ថិតនៅក្នុងបញ្ជីហាមប្រើនៅប្រទេសឥណ្ឌា | ១- ផ្តល់បញ្ជីហាមឃាត់សារធាតុសកម្ម ដែលហាមផលិតនិងហាមចែកចាយនេះ ជាលាយលក្ខណ៍អក្សរនិងជាផ្លូវការ។<br>២- បំភ្លឺពីសារធាតុសកម្ម ដែលពុំដូចទាំងស្រុងនៅក្នុងបញ្ជីហាមប្រើប្រាស់នោះ ថាតើអាចបន្តសុពលភាពឬចុះបញ្ជិកាបានឬទេ(សារធាតុសកម្មប្រហាក់ប្រហែលឬស្រដៀងគ្នា)។ | បានដោះស្រាយ |
| 3 | បញ្ហាផ្នែកពន្ធដារសម្រាប់វិស័យសុខាភិបាល | ស្នើសុំដល់ក្រសួងសុខាភិបាលសហការជាមួយផ្នែកឯកជន លើកសំណើជូនរាជរដ្ឋាភិបាលឱ្យលើកលែងពន្ធនិងសេវា ដែលត្រូវបង់ជូនដល់សាខាពន្ធដារនិងរដ្ឋបាលរាជធានីខេត្ត ចំពោះការដំឡើងបំណែកលើកស្លាកសញ្ញា ស្លាកព័ត៌មានសុខាភិបាល ឬស្លាកអប់រំសុខភាពដល់ប្រជាពលរដ្ឋ។ | បានដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| 4 | ប្រព័ន្ធCamPORS មានភាពអាក់អ្លួលនិងបាត់ឯកសារ | ស្នើដល់ក្រសួងសុខាភិបាល ដោះស្រាយចំពោះប្រព័ន្ធចុះប្រវេទន៍ CamPORS មានភាពអាក់អ្លួលនិងមានការបាត់ឯកសារចុះប្រវេទន៍មួយចំនួនផងនោះ។ | បានដោះស្រាយ |
| 5 | នីតិវិធីស្នើសុំការនាំចូលដោយរួចពន្ធគយអាករពិសេសនិងអាករលើតម្លៃបន្ថែម | ស្នើសុំក្នុងករណីគ្រឹះស្ថានផលិតឱសថ បានទទួលការឯកភាពជាគោលការណ៍ សម្ភារៈក្នុងការផ្តល់មតិនៃការស្នើសុំនាំចូលដោយរួចពន្ធគយអាករពិសេស និងអាករលើតម្លៃបន្ថែមដែលជាបន្ទុករបស់រដ្ឋនូវគ្រឿងម៉ាស៊ីន បរិក្ខារ និងវត្ថុធាតុដើមរបស់គ្រឹះស្ថានផលិតឱសថ (លើកលែងតែវត្ថុធាតុដើមNarcoticនិងPsychotrope) ពីក្រសួងសុខាភិបាលរួចហើយនោះ មិនគួរធ្វើការស្នើសុំនាំចូលជាក់ស្តែងពីក្រសួងសុខាភិបាលម្តងទៀតទេ។ | បានដោះស្រាយ |
| 6 | ការបណ្តុះបណ្តាលវិជ្ជាថែរក្សាសម្ផស្ស | សំណូមពរ គួរតែក្រសួងសុខាភិបាលជាអ្នកចេញអាជ្ញាបណ្ណចុះបញ្ជីបណ្តុះបណ្តាលវិជ្ជាជីវៈនេះ។ | កំពុងដោះស្រាយ |
| **ក្រុមការងារផ្នែកសំណង់ និងអចលនទ្រព្យ (ក្រុម«ខ»)** | | | |
| ឆ្នាំ២០២៤ | | | |
| 1 | ការបន្ធូរបន្ថយការប្រាក់លើកម្ចី សម្រាប់ការអភិវឌ្ឍលំនៅឋាននិងទិញអចលនទ្រព្យ | សំណើសុំការបន្ធូរបន្ថយការប្រាក់លើកម្ចីសម្រាប់ការអភិវឌ្ឍលំនៅឋាន និងទិញអចលនទ្រព្យ។ | កំពុងដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| **ក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមជីវភាព និងទូរគមនាគមន៍ (ក្រុម«ណ»)** | | | |
| ឆ្នាំ២០២៤ | | | |
| 1 | ការគាំទ្រដល់ការពង្រីកការគ្របដណ្ដប់ជនបទ និងប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល ដើម្បីឧបត្ថម្ភទៅលើការដាក់ពង្រាយនៅតាមជនបទ | ស្នើសុំពិនិត្យឡើងវិញចំពោះការគណនាស្ថិតិលើចំនួនគ្រួសារដែលអាចស្នើសុំប្រើប្រាស់មូលនិធិកាតព្វកិច្ចសេវាសកល។ | បានដោះស្រាយ |
| 2 | ភាពមិនច្បាស់លាស់នៃការបែងចែកវិសាលគមន៍ប្រេកង់វិទ្យុសម្រាប់៥G និងរយៈពេលនៃការដាក់ដំណើរការ៥G | ស្នើសុំការបែងចែកប្រេកង់វិទ្យុ ដើម្បីជំរុញការវិនិយោគ។ | បានដោះស្រាយ |
| 3 | ដោយហេតុថាការស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទចំពោះគ្រឿងអេឡិចត្រូនិកត្រូវបង់១០០០ដុល្លារអាម៉េរិក ក្នុងមួយឧបករណ៍ ក្រុមហ៊ុនដែលបំពេញកាតព្វកិច្ចបង់ពន្ធ ពុំអាចប្រកួតប្រជែងជាមួយក្រុមហ៊ុនដែលគេចពន្ធនិងក្រុមហ៊ុនអនឡាញ | ស្នើសុំកែសម្រួលលើនិយមន័យពាក្យ គ្រឿងសម្ភារៈបរិក្ខារទូរគមនាគមន៍និងវិទ្យុគមនាគមន៍ និងបន្ថយតម្លៃគ្រឿងអេឡិចត្រូនិកដែលមានភ្ជាប់សេវាអ៊ីនធឺណិតនិងប៊្លូធូស(Bluetooth)។ | កំពុងដោះស្រាយ |
| 4 | ការចុះឈ្មោះប្រើប្រាស់ដែនជាតិមានតម្លៃខ្ពស់ បើប្រៀបនឹងប្រទេសជិតខាង និងក្រុមហ៊ុនទាំងអស់ដែលចុះបញ្ជី គឺត្រូវបានតម្រូវឱ្យមានឈ្មោះដែនជាតិ ដែលរួមទាំងអាជីវកម្មបណ្ដុះធុរកិច្ចថ្មីផងដែរ | ស្នើសុំបញ្ចុះតម្លៃចុះឈ្មោះដែនជាតិ និងលើកលែងការស្នើសុំឈ្មោះដែនជាតិក្នុងរយៈពេលណាមួយចំពោះអាជីវកម្មបណ្ដុះធុរកិច្ចថ្មី។ | បានដោះស្រាយ |
| 5 | ក្រុមហ៊ុនដែលមិនទាន់ចុះបញ្ជី ទោះបីបានចុះបញ្ជីម៉ាក មិនអាចចុះឈ្មោះប្រើប្រាស់ដែនជាតិបាន | ស្នើសុំឱ្យមាននីតិវិធីថ្មីក្នុងការចុះឈ្មោះដែនជាតិ ដោយឈ្មោះដែលស្នើសុំ មិនចាំបាច់ដូចគ្នាទៅនឹងឈ្មោះរបស់ក្រុមហ៊ុននោះឡើយ និងអនុញ្ញាតឱ្យក្រុមហ៊ុនចុះឈ្មោះដែនជាតិបានច្រើនជាងមួយ។ | បានដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
| --- | --- | --- | --- |
| ឆមាសទី១ ឆ្នាំ២០២៥ | | | |
| 1 | ប្រកាសលេខ ២០៨ បទ. ប្រក ស្ដីពីការទទួលស្គាល់យថា-ប្រភេទ(Type Approval) លើបរិក្ខារវិទ្យុគមនាគមន៍ និង បរិក្ខារទូរគមនាគមន៍ | ស្នើសុំក្រសួងបញ្ជប់បទប្បញ្ញត្តិដែលតម្រូវឱ្យបង់ថ្លៃសេវាការនាំចូលសម្រាប់គ្រឿងអេឡិចត្រូនិក(Home Use) ដែលមានភ្ជាប់មុខងារសេវាអ៊ីនធឺណិតនិងប្លូធូស (Bluetooth)ដោយត្រឹមចុះឈ្មោះទទួលស្គាល់ជាគុណវឌ្ឍិបុគ្គល និងបង់សេវាប្រចាំដើម្បីទទួលស្គាល់ថាជាគុណវឌ្ឍិបុគ្គល ឬអ្នកនាំចូលគ្រឿងអេឡិចត្រូនិកដែលមានភ្ជាប់មុខងារសេវាអ៊ីនធឺណិត និងប្លូធូស(Bluetooth)។ | កំពុងដោះស្រាយ |
| 2 | គោលនយោបាយការអនុម័តប្រភេទ(Type Approval) សម្រាប់ឧបករណ៍AIនិងIoTs | ស្នើសុំលើកលែងការអនុម័តវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទសម្រាប់ឧបករណ៍AIនិងIoTs (បូករួមផ្ទះឆ្លាតវៃ(Smart Home) កសិដ្ឋានឆ្លាតវៃ(Smart Farm) និងសម្ភារៈប្រើប្រាស់ក្នុងផ្ទះ) សម្រាប់ប្រើប្រាស់ក្នុងលំនៅឋាននិងកសិកម្ម ជាពិសេសផលិតផលដែលជារបស់កម្ពុជា។ | កំពុងដោះស្រាយ |
| 3 | ស្នើសុំបទប្បញ្ញត្តិលម្អិត វិសាលភាព និង SOP នៃការស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ(Type Approval) ច្បាស់លាស់ | ១- ស្នើសុំបទប្បញ្ញត្តិច្បាស់លាស់និងផ្ដល់កាលវិភាគមុនពេលអនុវត្ត។<br>២- ស្នើសុំឱ្យមាន SOP នៃការស្នើសុំវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទ (Type Approval)និងរចនាសម្ព័ន្ធលំហូរជាលាយលក្ខណ៍អក្សរដើម្បីកុំឱ្យភាន់ច្រឡំ។<br>៣- ស្នើសុំឱ្យមានការបណ្តុះបណ្តាលច្បាស់លាស់ទាក់ទងនឹងបទប្បញ្ញត្តិថ្មីឬលំហូររចនាសម្ព័ន្ធថ្មីរបស់ក.ប.ទ។<br>៤- ស្នើសុំឱ្យមានមតិតបជាលាយលក្ខណ៍អក្សរផ្ដល់ដោយ ក.ប.ទ./ន.ទ.ក. តាមរយៈអ៊ីមែល ព្រោះវាជាការប្រើប្រាស់[illegible]របស់វិស័យឯកជន។ | កំពុងដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| 4 | ប្រកាសលេខ២០៨ បទ. ប្រក ស្ដីពីការទទួលស្គាល់យថាប្រភេទ(Type Approval) លើបរិក្ខារវិទ្យុគមនាគមន៍និងបរិក្ខារទូរគមនាគមន៍ | ១- ស្នើសុំចំណាត់ថ្នាក់ផលិតផលតាមប្រភេទ ដោយផ្អែកលើការប្រើប្រាស់ ឧទាហរណ៍គ្រឿងប្រើប្រាស់ក្នុងផ្ទះ គ្រឿងបរិក្ខារអគ្គិសនី ឧស្សាហកម្ម និងទូរគមនាគមន៍។<br>២- ស្នើសុំលើកលែងការបង់សេវា ពិនិត្យ និងសិក្សាច្បាប់នាំចូលស្ថិតក្រោមក.ប.ទ. ដើម្បីកំណត់ការលើកលែងថ្លៃឬអាករលើទំនិញដែលបានស្នើសុំ ដើម្បីកាត់បន្ថយចំណាយនាំចូលតាមច្បាប់។<br>៣- ស្នើសុំគ្រប់គ្រងការនាំចូលខុសច្បាប់និងគេចពន្ធ ដែលបង្កឱ្យមានការប្រកួតប្រជែងមិនស្មើភាព។ | កំពុងដោះស្រាយ |
| 5 | ស្វែងយល់ពីរបៀបក្នុងការចែកយថាប្រភេទ(TA) ពីន.ទ.ក. | ស្នើសុំន.ទ.ក. មានថ្នាលដើម្បីពិនិត្យស្វែងរកវិញ្ញាបនបត្រទទួលស្គាល់យថាប្រភេទលើឧបករណ៍នីមួយៗ។ | បានដោះស្រាយ |
| **ក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ (ក្រុម«ត»)** | | | |
| ឆមាសទី១ ឆ្នាំ២០២៥ | | | |
| 1 | ការត្រួតពិនិត្យអ្នកបើកបរដែលមានផ្ទុកឬប្រើប្រាស់សារធាតុញៀន | ស្នើសុំឱ្យម្ចាស់រថយន្តអាចដកយករថយន្តនិងទំនិញចេញ ដើម្បីយកទៅបន្តធ្វើអាជីវកម្មឱ្យបានទាន់ពេលវេលា ហើយសមត្ថកិច្ចអាចឃាត់ទុកអ្នកបើកបរ ដែលរកឃើញមានផ្ទុកឬប្រើប្រាស់សារធាតុញៀន។ | បានដោះស្រាយ |
| 2 | សំណើសុំកិច្ចសហប្រតិបត្តិការនិងចាត់វិធានការលើបទល្មើសបច្ចេកវិទ្យា(Cyber-Crime) | ១- ស្នើសុំក្រុមហ៊ុនទូរសព្ទ(Mobile Operator) តម្រូវឱ្យធានាអត្តសញ្ញាណអតិថិជនពេញលេញ(Full KYC) នៅពេលការទិញស៊ីមកាតទាំងអស់។ | កំពុងដោះស្រាយ |

| ល.រ. | បញ្ហាប្រឈម | សំណូមពរ | វឌ្ឍនភាព |
|---|---|---|---|
| | | ២- ស្នើសុំក្រុមហ៊ុនទូរសព្ទ បន្ថែមមុខងារការពារសុវត្ថិភាព ដើម្បីការពារទប់ស្កាត់បន្ថែមពីការធ្វើតំណភ្ជាប់ក្លែងក្លាយឬការធ្វើសារបោកបញ្ឆោតផ្សេងៗ។<br>៣- ស្នើសុំក្រុមហ៊ុនទូរសព្ទ មានការជូនដំណឹងទៅកាន់ម្ចាស់ស៊ីមកាតឱ្យដឹងករណីផុតកំណត់។ | |
| 3 | បញ្ហាប្រឈមចំពោះបច្ចេកទេសក្នុងការប្រើប្រាស់ជ្រូនកសិកម្ម | ១- ស្នើសុំឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសក្នុងការប្រើប្រាស់ជ្រូនកសិកម្ម និងនីតិវិធីតម្រូវផ្សេងៗទៅដល់ប្រជាកសិករជាមុនសិន មុននឹងចាប់ផ្តើមអនុវត្តច្បាប់ឬបទប្បញ្ញត្តិផ្សេងៗដែលបានចែងក្នុងប្រកាសអន្តរក្រសួង។<br>២- រាល់ពេលដែលមានតម្រូវការក្នុងការបង្ហោះជ្រូនកសិកម្មរបស់កសិករម្តងៗ គ្រាន់តែធ្វើការជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចបានហើយ កុំឱ្យមានការស្នើសុំច្បាប់ប្រើប្រាស់ ព្រោះនាំឱ្យខាតពេលវេលាក្នុងការរង់ចាំការអនុញ្ញាតពីអាជ្ញាធរ និងបង្កភាពស្មុគស្មាញដល់ប្រជាកសិករ។ | កំពុងដោះស្រាយ |

# បរិសិដ្ឋទី៤
# កម្រងសំណួរស្ទង់មតិ

**គោលបំណង :** ការស្ទង់មតិនេះ ត្រូវបានរៀបចំឡើង ដើម្បីប្រមូលមតិយោបល់កែលម្អពីតួអង្គពាក់ព័ន្ធ លើប្រសិទ្ធភាព នៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន និងការពេញចិត្តទៅលើសិក្ខាសាលាផ្សព្វផ្សាយ។ ចម្លើយរបស់លោកអ្នកពិតជាមានសារៈសំខាន់សម្រាប់ការវាយតម្លៃវឌ្ឍនភាពនៃកិច្ចសន្ទនារវាងរដ្ឋ-ឯកជន ក៏ដូចជាសម្រាប់ការកំណត់ទិសដៅសកម្មភាពរបស់រាជរដ្ឋាភិបាលនាពេលអនាគតដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជា។ កម្រងសំណួរនេះមាន២៩សំណួរហើយអាចនឹងចំណាយពេលប្រហែល១០នាទីដើម្បីបំពេញ។

*កំណត់សម្គាល់ : ការស្ទង់មតិនេះគឺមិនបញ្ចេញឈ្មោះទេ ហើយមិនមានទិន្នន័យផ្ទាល់ខ្លួនត្រូវបានប្រមូលនោះទេ។*

***សំណួរសម្រាប់តួអង្គពាក់ព័ន្ធទាំងអស់***

| ផ្នែក ក – ព័ត៌មានរបស់អ្នកចូលរួម | | |
|---|---|---|
| ក១ | សូមជ្រើសរើសភេទរបស់លោកអ្នក | ☐ ១- ប្រុស។<br>☐ ២- ស្រី។<br>☐ ៣- សូមមិនបញ្ជាក់។ |
| ក២ | តើលោកអ្នកបានចូលរួមវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅវិមានសន្តិភាពដែរឬទេ ? | ☐ ១- បាទ/ចាស។<br>☐ ២- ទេ។<br>☐ ៣- ទេ ប៉ុន្តែខ្ញុំបានដឹងអំពីG-PSF លើកទី១៩។ |
| ក៣ | តើលោកអ្នកបានចូលរួមក្នុងការស្ទង់មតិដែលបានធ្វើឡើងក្នុងកំឡុងពេលនៃពិធីផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាពG-PSF ប្រចាំឆមាសទី២ ឆ្នាំ២០២៤ កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៥(នៅសណ្ឋាគារ Shangri-La ) ដែរឬទេ ? | ☐ ១- បាទ/ចាស។<br>☐ ២- ទេ។ |
| ក៤ | តើលោកអ្នកជាតំណាងរបស់អង្គពាក់ព័ន្ធណាមួយ ? | ☐ ១-ស្ថាប័នរដ្ឋ(រំលងទៅកាន់ផ្នែកឃ)។<br>☐ ២- វិស័យឯកជន(បន្តទៅផ្នែកបន្ទាប់)។<br>☐ ៣- ដៃគូអភិវឌ្ឍ(រំលងទៅកាន់ផ្នែកង)។<br>☐ ៤-ផ្សេងៗ(សូមបញ្ជាក់):_______ (រំលងទៅកាន់ផ្នែក ង)។ |

| | | |
|---|---|---|
| ក៥ | តើលោកអ្នកស្ថិតនៅក្នុងក្រុមការងារតាមវិស័យណាមួយនៃG-PSF? (អ្នកស្ទង់មតិ ដែលបានជ្រើសរើសចម្លើយលេខ៣ និងលេខ៤ នៃសំណួរក៤ នឹងត្រូវរំលងសំណួរនេះ) | ☐ មិនមែនជាសមាជិកនៃក្រុមការងារ G-PSF ណាមួយឡើយ<br>**ក្រុមការងារឬវិស័យដែលពាក់ព័ន្ធនឹងលោកអ្នក៖**<br>☐ ក- ក្រុមការងារផ្នែកកសិកម្ម កសិឧស្សាហកម្ម។<br>☐ ខ- ក្រុមការងារផ្នែកទេសចរណ៍។<br>☐ គ- ក្រុមការងារផ្នែកកម្មន្តសាល សហគ្រាសធុនតូច និងមធ្យម និងសេវា។<br>☐ ឃ- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារនិងអភិបាលកិច្ច។<br>☐ ង- ក្រុមការងារផ្នែកសេវាធនាគារនិងហិរញ្ញវត្ថុ។<br>☐ ច- ក្រុមការងារផ្នែកដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ។<br>☐ ឆ- ក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម។<br>☐ ជ- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ។<br>☐ ឈ- ក្រុមការងារផ្នែកស្រូវអង្ករ។<br>☐ ញ- ក្រុមការងារផ្នែកថាមពលនិងធនធានរ៉ែ។<br>☐ ដ- ក្រុមការងារផ្នែកអប់រំ។<br>☐ ឋ- ក្រុមការងារផ្នែកសុខាភិបាល។<br>☐ ឌ- ក្រុមការងារផ្នែកសំណង់និងអចលនទ្រព្យ។<br>☐ ឍ- ក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុមិនមែនធនាគារ។<br>☐ ណ- ក្រុមការងារផ្នែកសេដ្ឋកិច្ច សង្គមឌីជីថល និងទូរគមនាគមន៍។<br>☐ ត- ក្រុមការងារផ្នែករដ្ឋបាលដែនដី សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ |

*សំណួរសម្រាប់អ្នកចូលរួមស្ទង់មតិពីវិស័យឯកជន*

| ផ្នែក ខ – ការយល់ឃើញលើវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ | | |
|---|---|---|
| ខ១ | សូមវាយតម្លៃការពេញចិត្តលើវិធានការដែលបានដាក់ចេញដោយG-PSF លើកទី១៩។ | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| ខ២ | គិតត្រឹមបច្ចុប្បន្ន សូមវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តវិធានការ ដែលបានដាក់ចេញដោយG-PSF លើកទី១៩។ | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។ |

| | | |
|---|---|---|
| | | ☐ ៥- មិនទាល់តែសោះ។ |
| ខ៣ | តើកំណែទម្រង់ដែលបានដាក់ចេញដោយG-PSF លើកទី១៩ អាចបង្កើនលទ្ធភាពអាជីវកម្មលោកអ្នកក្នុងសកម្មភាពណាមួយដែរឬទេ?<br>(អាចជ្រើសរើសបានច្រើនជាងមួយ) | ☐ ១- វិនិយោគបន្ថែមទៀតលើវិស័យផ្សេងៗ។<br>☐ ២- ជួលបុគ្គលិកបន្ថែម។<br>☐ ៣- ពង្រីកប្រតិបត្តិការអាជីវកម្ម។<br>☐ ៤- ផ្សេងៗ(សូមបកស្រាយបញ្ជាក់):______________។ |
| ខ៤ | សូមជ្រើសរើសផ្នែកកំណែទម្រង់ចំនួនបី ដែលលោកអ្នកគិតថានឹងមានឥទ្ធិពលវិជ្ជមានបំផុតលើអាជីវកម្មលោកអ្នកនៅកម្ពុជា។<br>(អាចជ្រើសរើសត្រឹមចំនួន៣) | ☐ ១- អភិបាលកិច្ច។<br>☐ ២- បទប្បញ្ញត្តិ/ច្បាប់។<br>☐ ៣- នីតិវិធីរដ្ឋបាល។<br>☐ ៤- នីតិវិធីនាំចេញ-នាំចូល។<br>☐ ៥- យុទ្ធសាស្ត្រ/គោលនយោបាយ។<br>☐ ៦- ពន្ធដារ។<br>☐ ៧- ឌីជីថល/បច្ចេកវិទ្យាព័ត៌មាន។<br>☐ ៨- ធនធានមនុស្ស។<br>☐ ៩- ហិរញ្ញវត្ថុ។<br>☐ ១០- ផ្សេងៗ(សូមបកស្រាបញ្ជាក់):______________។ |

***សំណួរសម្រាប់អ្នកចូលរួមស្ទង់មតិពីវិស័យឯកជន***

| ផ្នែក គ – ប្រសិទ្ធភាពក្រុមការងារតាមវិស័យ (WG) និងដំណើរការនៃG-PSF | | |
|---|---|---|
| គ១ | សូមវាយតម្លៃគុណភាពនៃកិច្ចសន្ទនានិងកិច្ចសហការរវាងរដ្ឋនិងវិស័យឯកជន នៅក្នុងក្រុមការងារតាមវិស័យលោកអ្នក។ | ☐ ១- ល្អប្រសើរ។<br>☐ ២- ល្អ។<br>☐ ៣- មធ្យម។<br>☐ ៤- ទាប។<br>☐ ៥- មិនមាន។ |
| គ២ | តើអ្វីជាបញ្ហាប្រឈមចម្បងដែលបន្ទប់បង្អាក់កិច្ចសហការប្រកបដោយប្រសិទ្ធភាពរវាងរដ្ឋនិងវិស័យឯកជនសម្រាប់G-PSF? (អាចជ្រើសរើសបានច្រើនជាងមួយ) | ☐ ១- ការឆ្លើយតបយឺតយ៉ាវ(ភាពយឺតយ៉ាវក្នុងការឆ្លើយតបឬការចាត់វិធានការពីខាងរាជរដ្ឋាភិបាល)។<br>☐ ២- កង្វះភាពច្បាស់លាស់(ព័ត៌មានឬសេចក្តីណែនាំមិនមានភាពច្បាស់លាស់ឬច្របូកច្របល់)។<br>☐ ៣- កង្វះការតាមដាន(បញ្ហាត្រូវបានលើកឡើង ប៉ុន្តែមិនត្រូវបានតាមដានឬធ្វើបច្ចុប្បន្នភាពជាប្រចាំ)។<br>☐ ៤- ការធ្វើទំនាក់ទំនងជាមួយមន្ត្រីពាក់ព័ន្ធនៅមានកម្រិត(មានភាពលំបាកក្នុងការទាក់ទងឬពិភាក្សាជាមួយមន្ត្រីពាក់ព័ន្ធ)។<br>☐ ៥- ផ្សេងៗ(សូមបញ្ជាក់):______________។ |
| គ៣ | តើរាជរដ្ឋាភិបាលយល់ច្បាស់ពីបញ្ហាដែលបានលើកឡើងដោយវិស័យឯកជនក្នុងកម្រិតណា? | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។ |

| | | |
|---|---|---|
| | | ☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| គ៤ | តើរាជរដ្ឋាភិបាលមានប្រសិទ្ធភាពក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានលើកឡើងដោយវិស័យឯកជនក្នុងកម្រិតណា? | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| គ៥ | តើលោកអ្នកត្រូវបានជូនដំណឹងជាប្រចាំអំពីស្ថានភាពឬដំណោះស្រាយនៃបញ្ហាដែលបានលើកឡើងដែរឬទេ? | ☐ ១- បាទ/ចាស។<br>☐ ២- ទេ។ |
| គ៦ | តើផ្នែកណាខ្លះនៃកិច្ចប្រជុំក្រុមការងារតាមវិស័យដែលទាមទារឱ្យមានការកែលម្អ?<br>(អាចជ្រើសរើសបានច្រើនជាងមួយ) | ☐ ១- រៀបចំកិច្ចប្រជុំក្រុមការងារតាមវិស័យជាប្រចាំ។<br>☐ ២- បង្កើនគុណភាពនៃការពិភាក្សានិងការដោះស្រាយបញ្ហា។<br>☐ ៣- កំណត់កាលវិភាគនៃការរៀបចំកិច្ចប្រជុំក្រុមការងារតាមវិស័យ ជាមួយនឹងការជូនដំណឹងជាមុន។<br>☐ ៤- ដោះស្រាយបញ្ហារបស់វិស័យឯកជនឱ្យបានឆាប់រហ័សជាមួយនឹងកាលកំណត់ច្បាស់លាស់។<br>☐ ៥- ពន្លឿនការរៀបចំរបាយការណ៍សង្ខេបនៃកិច្ចប្រជុំក្រុមការងារតាមវិស័យ។<br>☐ ៦- ធ្វើបច្ចុប្បន្នភាពជូនវិស័យឯកជនជាប្រចាំអំពីការសម្រេចចិត្ត និងលទ្ធផល ទោះបីជាបញ្ហានៅតែមិនទាន់ត្រូវបានដោះស្រាយក៏ដោយ។<br>☐ ៧- ផ្សេងៗ(សូមបញ្ជាក់): _____________។ |
| គ៧ | សូមវាយតម្លៃលើប្រសិទ្ធភាពនៃG-PSF ក្នុងការជំរុញឱ្យមានកំណែទម្រង់ដែលមានផលប្រយោជន៍ដល់អាជីវកម្មលោកអ្នក។ | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| គ៨ | តើលោកអ្នកមានសំណូមពរអ្វីខ្លះ ដើម្បីកែលម្អយន្តការ G-PSF ឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ភាគីពាក់ព័ន្ធទាំងអស់? | អត្ថបទ:<br>_______________________________________។ |

| ផ្នែក ឃ – ប្រសិទ្ធភាពក្រុមការងារតាមវិស័យ (WG) និងដំណើរការនៃG-PSF | | |
|---|---|---|
| ឃ១ | សូមវាយតម្លៃកម្រិតនៃការចូលរួមនិងកិច្ចសហការរបស់វិស័យឯកជននៅក្នុងក្រុមការងារតាមវិស័យនៃ G-PSF ដែលលោកអ្នកចូលរួម។ | ☐ ១- ល្អប្រសើរ។<br>☐ ២- ល្អ។<br>☐ ៣- មធ្យម។<br>☐ ៤- ទាប។<br>☐ ៥- មិនមាន។ |
| ឃ២ | សូមវាយតម្លៃគុណភាពនៃការឆ្លើយតបរបស់វិស័យឯកជន ទៅកាន់ការស្នើសុំព័ត៌មាន មតិយោបល់ ឬកិច្ចសហការរបស់រាជរដ្ឋាភិបាល។ (« គុណភាពនៃការឆ្លើយតប » សំដៅដល់ភាពឆាប់រហ័សនិងប្រសិទ្ធភាពនៃការឆ្លើយតប) | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| ឃ៣ | សូមវាយតម្លៃពីគុណភាពនៃបញ្ហា ដែលវិស័យឯកជនបានស្នើមកកាន់ក្រុមការងារតាមវិស័យ។ (« គុណភាពនៃបញ្ហា » សំដៅដល់ភាពពាក់ព័ន្ធ សារៈសំខាន់ និងគុណប្រយោជន៍នៃបញ្ហាដែលបានលើកឡើង) | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| ឃ៤ | តើធាតុចូលនិងអនុសាសន៍របស់វិស័យឯកជនមានគុណប្រយោជន៍កម្រិតណា ក្នុងការគាំទ្រកំណែទម្រង់គោលនយោបាយរបស់រាជរដ្ឋាភិបាល? | ☐ ១- ខ្លាំងបំផុត។<br>☐ ២- ខ្លាំង។<br>☐ ៣- មធ្យម។<br>☐ ៤- តិចតួច។<br>☐ ៥- មិនទាល់តែសោះ។ |
| ឃ៥ | តើលោកអ្នកជួបបញ្ហាប្រឈមសំខាន់ៗអ្វីខ្លះ នៅពេលអនុវត្តការងារជាមួយតំណាងវិស័យឯកជន? (អាចជ្រើសរើសបានច្រើនជាងមួយ) | ☐ ១- កម្រិតនៃការចូលរួមឬវត្តមានរបស់សមាជិកវិស័យឯកជនមានកម្រិត។<br>☐ ២- កង្វះភាពច្បាស់លាស់ក្នុងការស្នើសុំឬការពិពណ៌នាពីបញ្ហា។<br>☐ ៣- ការផ្តល់ឯកសារឬអំណះអំណាងគាំទ្រមិនគ្រប់គ្រាន់ពីវិស័យឯកជន។<br>☐ ៤- បញ្ហាដែលបានលើកឡើង គឺស្ថិតនៅក្រៅដែនសមត្ថកិច្ចរបស់ក្រុមការងារតាមវិស័យ។<br>☐ ៥- ការឆ្លើយតបឬផ្តល់មតិយោបល់ពីវិស័យឯកជនមានភាពយឺតយ៉ាវ។<br>☐ ៦- ការធ្វើទំនាក់ទំនងជាមួយវិស័យឯកជនមានការលំបាក។ |

| | | |
|---|---|---|
| | | □ ៧- ផ្សេងៗ(សូមបញ្ជាក់): ____________។ |
| ឃ៦ | តើផ្នែកណាខ្លះនៃការចូលរួមរបស់វិស័យឯកជន ដែលទាមទារឱ្យមានការកែលម្អ ដើម្បីពង្រឹងកិច្ចសហការរវាងរដ្ឋនិងវិស័យឯកជន? | □ ១- បង្កើនការចូលរួមក្នុងកិច្ចប្រជុំក្រុមការងារតាមវិស័យ។<br>□ ២- ផ្តល់ទិន្នន័យ/ភស្តុតាងបន្ថែម។<br>□ ៣- ធ្វើឱ្យប្រសើរឡើងនូវភាពទាន់ពេលវេលានៃការឆ្លើយតប។<br>□ ៤- ចែកចាយឯកសារប្រជុំឱ្យបានឆាប់ ដើម្បីអនុញ្ញាតឱ្យមានការត្រៀមលក្ខណៈបានល្អប្រសើរ។<br>□ ៥- បង្កើនសមត្ថភាពលេខាធិការដ្ឋានរបស់ក្រុមការងារតាមវិស័យផ្នែកឯកជន។<br>□ ៦- ផ្សេងៗ(សូមបញ្ជាក់): ____________។ |
| ឃ៧ | តើលោកអ្នកមានសំណូមពរអ្វីខ្លះ ដើម្បីកែលម្អយន្តការ G-PSF ឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ភាគីពាក់ព័ន្ធទាំងអស់? | អត្ថបទ :<br>______________________________________។ |

***សំណួរសម្រាប់តួអង្គពាក់ព័ន្ធទាំងអស់***

**ផ្នែក ង – ការស្ទង់មតិការពេញចិត្តទៅលើសិក្ខាសាលាផ្សព្វផ្សាយ**

ង១ សូមវាយតម្លៃការពេញចិត្តរបស់លោកអ្នកចំពោះសិក្ខាសាលាផ្សព្វផ្សាយនៅថ្ងៃនេះ តាមចំណុចនីមួយៗខាងក្រោម៖

| ចំណុចនៃសិក្ខាសាលាផ្សព្វផ្សាយ | ពេញចិត្តខ្លាំងណាស់ | ពេញចិត្តខ្លាំង | ពេញចិត្ត | មិនពេញចិត្ត | មិនពេញចិត្តខ្លាំង |
|---|---|---|---|---|---|
| ទិដ្ឋភាពទូទៅនៃសិក្ខាសាលាផ្សព្វផ្សាយ | ○ | ○ | ○ | ○ | ○ |
| បន្ទប់ប្រជុំ | ○ | ○ | ○ | ○ | ○ |
| អាហារសម្រន់ | ○ | ○ | ○ | ○ | ○ |
| ទីតាំងសណ្ឋាគារ | ○ | ○ | ○ | ○ | ○ |
| ប្រព័ន្ធសំឡេង | ○ | ○ | ○ | ○ | ○ |
| ឯកសារដែលបានចែកជូន | ○ | ○ | ○ | ○ | ○ |
| របៀបវារៈនិងពេលវេលា | ○ | ○ | ○ | ○ | ○ |
| សំណួរ ចម្លើយ និងការពិភាក្សា | ○ | ○ | ○ | ○ | ○ |

| | | |
|---|---|---|
| ង២ | តើបាយការណ៍វឌ្ឍនភាពដែលបានបង្ហាញនៅថ្ងៃនេះ មានប្រយោជន៍សម្រាប់លោកអ្នកក្នុងកម្រិតណាដែរ? | ☐ ១- មានប្រយោជន៍ខ្លាំង។<br>☐ ២- មានប្រយោជន៍បង្គួរ។<br>☐ ៣- មានប្រយោជន៍[illegible]<br>☐ ៤- មិនមានប្រយោជន៍។<br>☐ ៥- មិនមានប្រយោជន៍ទាល់តែសោះ។ |

| | | |
|---|---|---|
| ង៣ | តើសិក្ខាសាលាផ្សព្វផ្សាយនៅថ្ងៃនេះបានប្រព្រឹត្តទៅតាមការរំពឹងទុករបស់លោកអ្នកដែរឬទេ? | ☐ ១- លើសពីការរំពឹងទុក។<br>☐ ២- ដូចការរំពឹងទុក។<br>☐ ៣- ដូចការរំពឹងទុកខ្លះដែរ។<br>☐ ៤- មិនដូចការរំពឹងទុកទេ។ |
| ង៤ | សូមលោកអ្នកវាយតម្លៃឱកាសក្នុងការចូលរួមរបស់លោកអ្នក កំឡុងពេលនៃសិក្ខាសាលាផ្សព្វផ្សាយនៅថ្ងៃនេះដូចខាងក្រោម៖ | ☐ ១- ពេញចិត្តខ្លាំងណាស់។<br>☐ ២- ពេញចិត្តខ្លាំង។<br>☐ ៣- ពេញចិត្ត។<br>☐ ៤- មិនពេញចិត្ត។<br>☐ ៥- មិនពេញចិត្តខ្លាំង។ |
| ង៥ | តើលោកអ្នកចង់ទទួលបានព័ត៌មានដែលពាក់ព័ន្ធនឹង G-PSF អ្វីខ្លះ? | ☐ ១- ព័ត៌មានពាក់ព័ន្ធកិច្ចប្រជុំនៃវិស័យឯកជន(PSWGs) និងក្រុមការងារតាមវិស័យ(WGs)។<br>☐ ២- របៀបវារៈកិច្ចប្រជុំក្រុមការងារតាមវិស័យ(WGs)។<br>☐ ៣- សេចក្តីសង្ខេប ឬរបាយការណ៍ពីកិច្ចប្រជុំក្រុមការងារតាមវិស័យ(WGs)។<br>☐ ៤- ការជូនដំណឹងនៅពេលដែលបញ្ហាពីក្រុមការងារតាមវិស័យ(WGs) ត្រូវបានអនុវត្ត។<br>☐ ៥- ផ្សេងៗ________________________________។ |

រៀបរៀង និងបោះពុម្ពដោយ៖

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

លេខទូរសព្ទ (+៨៥៥) ០៩៩ ៧៩៩ ៥៧៩
(+៨៥៥) ០៩៨ ៧៩៩ ៥៧៩

អាសយដ្ឋាន វិមានរដ្ឋាភិបាល តីរវិថីព្រះស៊ីសុវត្ថិ វត្តភ្នំ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

គេហទំព័រ cdc.gov.kh ; cib-cdc.gov.kh

គាំទ្រដោយ៖

Australian Aid

CAPRED

**រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់**

អាសយដ្ឋាន អគារ GIA Tower ជាន់ទី ១៧
ផ្លូវសុភមង្គល កោះពេជ្រ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

គេហទំព័រ capred.org